**មាតិកា** ទំព័រ


១. លក្ខខណ្ឌទូទៅ..........២

២. ពាក្យ និងនិយមន័យ..........២

៣. កាតព្វកិច្ចរបស់អតិថិជន..........២

៤. គណនី និងសេវាកម្ម..........៥

៥. ការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងការគ្រប់គ្រងការដាក់ទណ្ឌកម្ម..........១០

៦. របាយការណ៍គណនី យោបល់បញ្ជាក់ និងសេវាកម្មធ្វើរបាយការណ៍..........១១

៧. កម្រៃជើងសារ កម្រៃសេវា សោហ៊ុយ ចំណាយ និងពន្ធ..........១១

៨. ការបញ្ចប់ និងការព្យួរ..........១២

៩. សំណងការខូចខាត..........១៤

១០. ការកម្រិតលើការទទួលខុសត្រូវ..........១៥

១១. ការទូទាត់កាត់កងប្រាក់..........១៦

១២. ការបង្ហាញព័ត៌មាន..........១៦

១៣. ការបោះបង់សិទ្ធិ..........១៧

១៤. ការផ្ទេរសិទ្ធិ..........១៧

១៥. ប្រការផ្សេងៗ..........១៨

១៦. ការជូនដំណឹង..........១៩

១៧. ច្បាប់គ្រប់គ្រង និងយុត្តាធិការ..........១៩

១៨. ពន្ធ..........២០

១៩. អត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយ..........២០

## បញ្ញត្តិ និងលក្ខខណ្ឌទូទៅ

ការបើកគណនី ការធ្វើប្រតិបត្តិការទូទៅ និងការបិទ**គណនី ផលិតផល** និង**សេវាកម្ម** នៅធនាគារ ព្រីនស៍ ម.ក (PRINCE BANK PLC.) ត្រូវគ្រប់គ្រងដោយបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ ("**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ**") ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់ណាមួយផ្សេងទៀត ("**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់**") ដែលអនុវត្តចំពោះ**ផលិតផល** និង**សេវាកម្ម**ជាក់លាក់នីមួយៗ ហើយក៏អាចត្រូវបានបន្ថែម ធ្វើវិសោធនកម្ម ផ្លាស់ប្តូរ លុបចោល និងកែប្រែនៅពេលណាមួយនាពេលអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់របស់ ធនាគារ ព្រីនស៍ ម.ក ទោះបីដោយមាន ឬគ្មានការជូនដំណឹងជាមុន ហើយ**អតិថិជន** យល់ព្រមគោរព និងបន្តអនុវត្តកាតព្វកិច្ចស្រប តាម**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** និង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់**ទាំងនេះ រួមបញ្ចូលទាំងការធ្វើវិសោធនកម្ម ការផ្លាស់ប្តូរ ការលុបចោល និងការកែប្រែលើនោះ និងការចុះផ្សាយលើគេហទំព័រផ្លូវការរបស់ធនាគារ ព្រីនស៍ ម.ក ដូចមានចែងខាងក្រោម៖

### ១. លក្ខខណ្ឌទូទៅ

លើកលែងតែមានចែងផ្សេងពីនេះនៅក្នុង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់ បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ខាងក្រោមត្រូវយកមកអនុវត្តចំពោះ**គណនី ផលិតផល** និង**សេវាកម្ម**ទាំងអស់ ដែលផ្តល់ដោយធនាគារ ព្រីនស៍ ម.ក ។ **អតិថិជន**ត្រូវយកចិត្តទុកដាក់អាន និងយល់ឱ្យបានច្បាស់នូវគ្រប់បញ្ញត្តិ និងលក្ខខណ្ឌនីមួយៗ រួមបញ្ចូលទាំង ការធ្វើវិសោធនកម្ម ការផ្លាស់ប្តូរ ការលុបចោល និងការកែប្រែណាមួយដែលបានធ្វើឡើងនៅពេលណាមួយនាពេលអនាគត  នៅមុនពេលប្រើប្រាស់**គណនី ផលិតផល** និង**សេវាកម្ម**ណាមួយ ឬធ្វើការសាកសួរទំនាក់ទំនងជាមួយនឹងមន្ត្រីរបស់ធនាគារ ព្រីនស៍ ម.ក។

### ២. ពាក្យ និងនិយមន័យ

លើកលែងតែបានកំណត់និយមន័យផ្សេងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ រាល់ពាក្យដែលខាងក្រោមប្រើប្រាស់ក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ត្រូវមានអត្ថន័យដូចបានផ្តល់ឱ្យនៅក្នុង **ឧបសម្ព័ន្ធ ១ (ពាក្យបានកំណត់ និងនិយមន័យ)** របស់**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ**នេះ។

### ៣. កាតព្វកិច្ចរបស់អតិថិជន

ដើម្បីទទួលបាន និងប្រើប្រាស់**គណនី ផលិតផល** និង**សេវាកម្ម** ពីធនាគារ ព្រីនស៍ ម.ក **អតិថិជន**យល់ព្រមថា៖

៣.១. ព័ត៌មាន

ក. ផ្តល់នូវឯកសារចុះបញ្ជី ឬអត្តសញ្ញាណមានសុពលភាព និងឯកសារផ្សេងទៀត ដូចបានកំណត់ដោយធនាគារ ព្រីនស៍ ម.ក នៅពេលណាមួយនាពេលអនាគតសម្រាប់ការបើក/ការបិទ ឬធ្វើប្រតិបត្តិការ **គណនី ផលិតផល** និង**សេវាកម្ម**ជាមួយធនាគារ ព្រីនស៍ ម.ក។

ខ. ផ្តល់ជូនធនាគារ ព្រីនស៍ ម.ក នូវរាល់ព័ត៌មាន និងឯកសារ ដែលធនាគារ ព្រីនស៍ ម.ក ស្នើសុំដោយសមស្របនៅពេលណាមួយនាពេលអនាគត។ **អតិថិជន**ទទួលស្គាល់ថា រាល់ព័ត៌មានទាំងអស់ដែលបានផ្តល់ជូនធនាគារ ព្រីនស៍ ម.ក ត្រូវមានភាពត្រឹមត្រូវ ពេញលេញ ជាព័ត៌មានចុង

ក្រោយ និងគ្មានការបន្លំ ។ **អតិថិជន**ត្រូវធានាថា ឯកសារទាំងអស់ដែលបានផ្តល់ជូនធនាគារ ព្រីនស៍ ម.ក នៅតែមានសុពលភាពគ្រប់ពេលវេលា។

គ. ជូនដំណឹងទៅធនាគារ ព្រីនស៍ ម.ក ជាលាយលក្ខណ៍អក្សរភ្លាមតាមដែលអាចធ្វើទៅបាន នូវរាល់ការផ្លាស់ប្តូរព័ត៌មានណាមួយ ដែលបានផ្តល់ជូនទៅធនាគារ ព្រីនស៍ ម.ក ដូចជា ការកែប្រែហត្ថលេខា/ហត្ថលេខី ការកែប្រែអាសយដ្ឋាន ឬព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានរបស់ក្រុមហ៊ុនណាមួយ។ **អតិថិជន**យល់ព្រមផងដែរថា រហូតដល់ពេលដែល**អតិថិជន**បានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីការកែប្រែខាងលើនោះទៅធនាគារ ព្រីនស៍ ម.ក ហើយធនាគារមានឱកាសសមស្របក្នុងការចាត់វិធានការតាមការជូនដំណឹងនោះ ធនាគារ ព្រីនស៍ ម.ក នៅតែបន្តប្រើប្រាស់ព័ត៌មានដែលបាន ផ្តល់ជូនដោយអតិថិជនពីមុនបាន។ ធនាគារ ព្រីនស៍ ម.ក មិនទទួលខុសត្រូវលើការបាត់បង់ណាមួយ ដែលកើតមានចំពោះ**អតិថិជន** ទាក់ទងនឹងការកែប្រែណាមួយ ដែលមិនបានជូនដំណឹងត្រឹមត្រូវទៅធនាគារ ព្រីនស៍ ម.ក នោះឡើយ។

ឃ. ផ្តល់ជូនធនាគារ ព្រីនស៍ ម.ក នូវព័ត៌មាន និងឯកសារចាំបាច់ទាំងអស់ ដែលធនាគារ ព្រីនស៍ ម.ក ស្នើសុំដោយសមស្របនៅពេលណាមួយនាពេលអនាគត ទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម**។

ង. ធានាថារាល់**គណនី**ដែលបានរក្សា និងធ្វើប្រតិបត្តិការជាមួយនឹងធនាគារ ព្រីនស៍ ម.ក ក៏ដូចជាឯកសារទាំងអស់ រួមមានជាអាទិ៍ សៀវភៅប្រាក់បញ្ញើសំចៃ សៀវភៅមូលប្បទានប័ត្រ និងប័ណ្ណទទួលប្រាក់បញ្ញើ ដែលបានចេញដោយធនាគារ ព្រីនស៍ ម.ក ទាក់ទងនឹង**គណនី**ណាមួយ មិនអាចយកទៅប្រើប្រាស់ជាទ្រព្យធានាក្នុងទម្រង់ណាមួយឡើយ ទោះបីជាបាន ឬមិនបានចុះបញ្ជីដោយ**អតិថិជន** ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរច្បាស់លាស់ពីធនាគារ ព្រីនស៍ ម.ក ដែលមានឆន្ទានុសិទ្ធិបដិសេធការយល់ព្រម ដោយមិនចាំបាច់មានកាតព្វកិច្ចផ្តល់នូវហេតុផលណាមួយ សម្រាប់ការបដិសេធនោះឡើយ។

ច. ជូនដំណឹងទៅធនាគារ ព្រីនស៍ ម.ក ភ្លាមតាមដែលអាចអនុវត្តបាន នូវរាល់កំហុស វិវាទ ឬការសង្ស័យ ការក្លែងបន្លំ ឬភាពផ្ទុយច្បាប់ ទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម** ឬ**បញ្ហា**ណាមួយ ឱ្យទៅ ធនាគារ ព្រីនស៍ ម.ក សម្រាប់ការប្រើប្រាស់**គណនី ផលិតផល** និង**សេវាកម្ម**ពាក់ព័ន្ធ។

ឆ. ផ្ទៀងផ្ទាត់ និងបញ្ជាក់ថា ព័ត៌មានលម្អិតទាំងអស់ក្នុងប័ណ្ណដាក់ប្រាក់ ផ្ទេរប្រាក់ ឬដកប្រាក់ ត្រូវបានបំពេញយ៉ាងពេញលេញ និងត្រឹមត្រូវ ហើយរាល់ការកែប្រែលើប័ណ្ណពាក់ព័ន្ធនោះត្រូវតែចុះហត្ថលេខាយ៉ាងពេញលេញដោយ**អតិថិជន**។ ធនាគារ ព្រីនស៍ ម.ក រក្សាសិទ្ធិក្នុងការធ្វើវិសោធនកម្ម/កែប្រែ ក្នុងករណីដែលមានការបន្ថែមខុស និង/ឬ មានកំហុសនានា និង

ជ. ជូនដំណឹងទៅធនាគារ ព្រីនស៍ ម.ក ភ្លាមតាមដែលអាចអនុវត្តបាន អំពីការកើតឡើងនូវការបំពាន ឬ ស្ថានភាពដែលអាចនឹងមានការបំពាន ប្រការណាមួយក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ**នេះ ព្រមទាំង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់**ពាក់ព័ន្ធណាមួយផ្សេងទៀត។

៣.២. ករណីកិច្ចប្រុងប្រយ័ត្ន

ក. បានទទួលការអនុញ្ញាតចាំបាច់ទាំងអស់ ដែលតម្រូវ ដោយច្បាប់ និងបទប្បញ្ញត្តិណាមួយជាធរមាន រួមបញ្ចូលទាំង ការអនុញ្ញាត ប្រសិនបើមាន ពី**អាជ្ញាធរ**មានសមត្ថកិច្ច ដើម្បីឱ្យ**អតិថិជន** អាចបើក រក្សា និងធ្វើប្រតិបត្តិការលើ**គណនី ផលិតផល** និង**សេវាកម្ម**ជាមួយធនាគារ ព្រីនស៍ ម.ក ។

ខ. គោរពតាមការណែនាំ និងនីតិវិធីទាំងអស់ដែលធនាគារ ព្រីនស៍ ម.ក ដាក់ចេញនៅពេលណាមួយនាពេលអនាគត ទាក់ទងនឹងប្រតិបត្តិការ ឬការប្រើប្រាស់**គណនី ផលិតផល** និង**សេវាកម្ម** រួមមានដោយមិនកម្រិតត្រឹមតែ ការត្រួតពិនិត្យ អត្តសញ្ញាណ នីតិវិធីផ្ទៀងផ្ទាត់ ឬនីតិវិធីសុវត្ថិភាព ដែលធនាគារ ព្រីនស៍ ម.ក យកមកប្រើប្រាស់ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវ និងសុពលភាពរបស់**បញ្ជា**ណាមួយ ឬមុននឹងអនុវត្តលើ**គណនី ផលិតផល** និង**សេវាកម្ម** ឬផ្នែកណាមួយនោះ។

គ. ធ្វើការវាយតម្លៃផ្ទាល់ខ្លួនថាតើ លោកអ្នកបានអនុលោមតាមច្បាប់ បទប្បញ្ញត្តិ ឬកាតព្វកិច្ចពន្ធ ឬកាតព្វកិច្ចណាមួយ ទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម** និងគ្រប់ពេលវេលាត្រូវតែគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន និងកាតព្វកិច្ច**ពន្ធ** និងកាតព្វកិច្ចណាមួយនោះ។ **អតិថិជន**ទទួលស្គាល់ថា ធនាគារ ព្រីនស៍ ម.ក មិនមានផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ ពន្ធដារ ឬគណនេយ្យ ឬវិជ្ជាជីវៈផ្សេងណាមួយនោះទេ ទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម** ឬការប្រឹក្សាយោបល់ទាក់ទងនឹងភាពសមស្រប ឬភាពចំណេញ នៃប្រតិបត្តិការណាមួយពាក់ព័ន្ធនឹង**គណនី ផលិតផល** និង**សេវាកម្ម** ។

**ឃ.**ប្រើប្រាស់វិធានការប្រុងប្រយ័ត្នសមរម្យទាំងអស់ ដើម្បីបង្ការការក្លែងបន្លំ ឬការចូលទៅកាន់ និងប្រើប្រាស់**គណនី ផលិតផល** និង**សេវាកម្ម** ដោយគ្មានការអនុញ្ញាត។

៣.៣. **បុគ្គលដែលទទួលបានការអនុញ្ញាត**

ថា៖

ក. **បុគ្គលដែលទទួលបានការអនុញ្ញាត**នីមួយៗត្រូវបានអនុញ្ញាតដោយ**អតិថិជន** ដើម្បីផ្តល់**បញ្ជា** អនុវត្តសកម្មភាព ឬកាតព្វកិច្ចណាមួយដូចមានចែងក្នុង**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធណាមួយផ្សេងទៀត ក្នុងនាម**អតិថិជន** ដែលចងភ្ជាប់កាតព្វកិច្ចលើ**អតិថិជន** ស្របតាម**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធណាមួយផ្សេងទៀត និងប្រតិបត្តិការណាមួយទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម**។

ខ. **អតិថិជន** ត្រូវទទួលខុសត្រូវចំពោះធនាគារ ព្រីនស៍ ម.ក ចំពោះ**បញ្ជា**ដែលបានចុះហត្ថលេខា ផ្តួចផ្តើម បញ្ជូន ឬផ្តល់ដោយ**បុគ្គលដែលទទួលបានការអនុញ្ញាត** និងសកម្មភាពទាំងអស់របស់**បុគ្គលដែលទទួលបានការអនុញ្ញាត** (រួមបញ្ចូលទាំងកម្រៃ សោហ៊ុយ និងបំណុល ដែលបានកើតមាន ឬនឹងកើតមាន ឬចេញពី**បញ្ជា** ឬសកម្មភាពនោះ)។

គ. ធនាគារ ព្រីនស៍ ម.ក អាចពឹងផ្អែកលើ**បញ្ជា** ឬ កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ផ្តួចផ្តើម បញ្ជូន ឬផ្តល់ដោយ**បុគ្គលដែលទទួលបានការអនុញ្ញាត**ដែលអះអាង ឬបង្ហាញថា បានចុះហត្ថលេខា ផ្តួចផ្តើម បញ្ជូន ឬផ្តល់ដោយ**បុគ្គលដែលទទួលបានការអនុញ្ញាត**នោះពិតប្រាកដ ដែលបង្ហាញថាខ្លួនបានចុះហត្ថលេខា ផ្តួចផ្តើម បញ្ជូន ឬផ្តល់ឱ្យ ទោះបីជា **អតិថិជន** ចោទប្រកាន់ថា **បញ្ជា** ឬកិច្ចព្រមព្រៀងនោះមិនត្រូវបានអនុញ្ញាតដោយ**អតិថិជន**ក៏ដោយ។

ឃ.**បុគ្គលដែលទទួលបានការអនុញ្ញាត**នីមួយៗ នឹងបន្តទទួលបានការអនុញ្ញាតរហូតដល់ពេលដែលធនាគារ ព្រីនស៍ ម.ក ទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរត្រឹមត្រូវពី**អតិថិជន** ក្នុងទម្រង់បែបបទកំណត់ដោយធនាគារ ព្រីនស៍ ម.ក ផ្ទុយពីនេះ និងរហូតដល់ពេលទទួលបានការជូនដំណឹងនោះ បើមិនដូច្នេះទេធនាគារ ព្រីនស៍ ម.ក នៅតែមានសិទ្ធិពឹងផ្អែកលើ ហើយនឹងត្រូវបានការពារយ៉ាងពេញលេញក្នុងការធ្វើសកម្មភាព ដោយផ្អែកលើព័ត៌មានទាក់ទងនឹង**បុគ្គលដែលទទួលបានការអនុញ្ញាត**ដែលបានផ្តល់ឱ្យខ្លួនពីមុន។

ង. ធនាគារ ព្រីនស៍ ម.ក អាចតម្រូវឱ្យ**បុគ្គលដែលទទួលបានការអនុញ្ញាត**នីមួយៗ ផ្តល់អត្តសញ្ញាណទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ឬការតម្រូវផ្សេងសមស្របណាមួយដែលបានកំណត់ដោយធនាគារ ព្រីនស៍ ម.ក នៅពេលណាមួយនាពេលអនាគត។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារ ព្រីនស៍ ម.ក អាចមិនអនុវត្ត ឬធ្វើសកម្មភាពតាម**បញ្ជា** រហូតដល់ខ្លួនបានបញ្ចប់ដំណើរការផ្ទៀងផ្ទាត់លើការត្រួតពិនិត្យអត្តសញ្ញាណ ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ ។

## ៤. គណនី និងសេវាកម្ម

៤.១. ធនាគារ ព្រីនស៍ ម.ក ត្រូវបើក និងរក្សា**គណនី**មួយ ឬច្រើន សម្រាប់**អតិថិជននៅពេលណាមួយនាពេលអនាគត** ដែលកំពុងមានបច្ចុប្បន្ន តាមការយល់ព្រមរបស់ ធនាគារ ព្រីនស៍ ម.ក។

ទាក់ទងនឹង**គណនី**ណាមួយៈ

១. CASA និងប្រាក់បញ្ញើមានកាលកំណត់ៈ **អតិថិជន**អាចបើក និងរក្សាគណនីចរន្ត គណនីបញ្ញើសំចៃ និងគណនីរូបិយប័ណ្ណបរទេស ("**CASA**") និងគណនីប្រាក់បញ្ញើមានកាលកំណត់ ("**ប្រាក់បញ្ញើមានកាលកំណត់**") ជាមួយធនាគារ ព្រីនស៍ ម.ក និងអនុលោមតាម **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** របស់ CASA និងប្រាក់បញ្ញើមានកាលកំណត់។

២. ប្រសិនបើប្រទេសដើមនៃរូបិយប័ណ្ណ ដាក់កម្រិតលើការប្រើប្រាស់ឥណទាន ឬការផ្ទេរមូលនិធិ ជារូបិយប័ណ្ណនោះ ធនាគារ ព្រីនស៍ ម.ក នឹងមិនមានកាតព្វកិច្ចបង់ប្រាក់ពី**គណនី**ណាមួយ នូវមូលនិធិជារូបិយប័ណ្ណនោះទេ។ ធនាគារ ព្រីនស៍ ម.ក អាច (ប៉ុន្តែមិនមានកាតព្វកិច្ច) អនុវត្តកាតព្វកិច្ចរបស់ខ្លួន ទាក់ទងនឹងមូលនិធិនោះ ដោយបង់ប្រាក់ទៅ**អតិថិជន**នៅពេលណាមួយ (ទោះបីជា មុន ឬក្រោយកាលកំណត់សង) នូវមូលនិធិនោះក្នុងរូបិយប័ណ្ណផ្សេងតាមអត្រាប្តូរប្រាក់ និងក្នុងរបៀបណាមួយដែលធនាគារ ព្រីនស៍ ម.ក កំណត់តាមឆន្ទានុសិទ្ធិរបស់ខ្លួន ។ **អតិថិជន**យល់ព្រមថា

រាល់ការទូទាត់នោះត្រូវបង្កើតជាការរំលត់ ត្រឹមត្រូវ មានសុពលភាព និងពេញលេញ នូវកាតព្វកិច្ច របស់ធនាគារ ព្រីនស៍ ម.ក ចំពោះ**អតិថិជន** ទាក់ទងនឹងមូលនិធិនោះ។

៣. ដោយមិនប៉ះពាល់ដល់ប្រការខាងលើ **អតិថិជន** ទទួលស្គាល់ថា រាល់គណនីប្រាក់បញ្ញើសំចៃជារូបិយប័ណ្ណបរទេស ("គណនីរូបិយប័ណ្ណបរទេស") មានការប្រែប្រួលទៅតាមស្ថានភាពទីផ្សារទូទៅ ដែលនៅពេលដល់ពេលកាលកំណត់សង អាចនាំមកនូវការចំណេញ ឬការខាតបង់ប្រាក់ចំណូល និង/ឬ ការវិនិយោគ។ និង

ឃ. **អតិថិជន** ទទួលស្គាល់ដែរថា ការបើកគណនីរូបិយប័ណ្ណបរទេស ត្រូវអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដូចដែលបានកំណត់ដោយធនាគារ ព្រីនស៍ ម.ក នៅពេលណាមួយនាពេលអនាគត ។

៤.២. ប្រាក់បញ្ញើ និងបង្កាន់ដៃ

**ក.** ទាក់ទងនឹងការដាក់ប្រាក់បញ្ញើជាសាច់ប្រាក់ទៅក្នុង**គណនី**ណាមួយ៖

១. ការដាក់ប្រាក់បញ្ញើទាំងអស់ត្រូវភ្ជាប់មកជាមួយនូវប័ណ្ណដាក់ប្រាក់បញ្ញើ ហើយការដាក់ប្រាក់បញ្ញើនោះ ត្រូវបានកំណត់យ៉ាងជាក់លាក់ដោយធនាគារ ព្រីនស៍ ម.ក ។ ធនាគារ ព្រីនស៍ ម.ក មានសិទ្ធិបដិសេធសាច់ប្រាក់សម្រាប់បញ្ញើណាមួយ ប្រសិនបើធនាគារ ព្រីនស៍ ម.ក មិនពេញចិត្ត នូវប្រភពដើមរបស់សាច់ប្រាក់នោះតាមឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន ។

២. ប្រសិនបើធនាគារ ព្រីនស៍ ម.ក យល់ព្រមទទួលប្រាក់បញ្ញើជាសាច់ប្រាក់ក្នុងរូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណខ្មែររៀល (**ខ្មែររៀល**) **អតិថិជន**យល់ព្រមថា ធនាគារ ព្រីនស៍ ម.ក អាចប្តូរសាច់ប្រាក់ដែលបានទទួលនោះពី**អតិថិជន**ទៅជា **ដុល្លារអាមេរិក** ទៅតាម**អត្រាដែលត្រូវអនុវត្ត**។ និង

៣. **អតិថិជន** ទទួលស្គាល់ និងយល់ព្រមថា ប័ណ្ណដាក់ប្រាក់បញ្ញើ មិនមែនជាបង្កាន់ដៃដែលមានសុពលភាព ឬឯកសារបញ្ជាក់កម្មសិទ្ធិទេ ប្រសិនបើចំនួនប្រាក់ដែលបានបង្ហាញនៅលើប័ណ្ណដាក់ប្រាក់បញ្ញើ ខុសពីការរាប់សាច់ប្រាក់របស់ធនាគារ ព្រីនស៍ ម.ក ហើយការរាប់សាច់ប្រាក់របស់ធនាគារ ព្រីនស៍ ម.ក ត្រូវចាត់ទុកជាការរាប់ចុងក្រោយ និងស្ថាពរ។

**ខ.** ទាក់ទងនឹងការដាក់ប្រាក់បញ្ញើជាមូលប្បទានប័ត្រដែលបានធ្វើឡើងទៅក្នុង**គណនី**ណាមួយ៖

១. នៅពេលមូលប្បទានប័ត្រ (ទោះត្រូវដកនៅធនាគារក្នុងស្រុក ឬបរទេស) ត្រូវបានដាក់ប្រាក់បញ្ញើសម្រាប់ឥណទានទៅ**គណនី** ធនាគារ ព្រីនស៍ ម.ក មិនមានកាតព្វកិច្ចចុះឥណទានចូល**គណនី**ភ្លាមៗ ហើយអាចមិនចុះឥណទានចូល**គណនី** រហូតដល់ និងលុះត្រាតែឥណទាននោះត្រូវបានចាត់ទុកជា**មូលនិធិច្បាស់លាស់**។

២. ធនាគារ ព្រីនស៍ ម.ក នឹងធ្វើឥណពន្ធ**គណនី**ជាមួយនឹងចំនួនទឹកប្រាក់ ដែលបានចុះឥណទានរួមជាមួយនឹង សោហ៊ុយ ការប្រាក់ និងកម្រៃជើងសារ ដែលត្រូវអនុវត្តទាក់ទងនឹងប្រតិបត្តិការ

នេះ ប្រសិនបើមូលប្បទានប័ត្រនោះ ត្រូវបានបដិសេធ ឬមិនអាចទូទាត់បាន ដោយហេតុផលណាមួយ។

៣. ធនាគារ ព្រីនស៍ ម.ក មានឆន្ទានុសិទ្ធិផ្តាច់មុខក្នុងការទទួល ឬបដិសេធមូលប្បទានប័ត្រណាមួយសម្រាប់ដាក់ប្រាក់បញ្ញើ ដែលធនាគារ ព្រីនស៍ ម.ក យល់ឃើញថា មានភាពមិនប្រក្រតីក្នុងលក្ខណៈណាមួយ ឬត្រូវបានកែប្រែដោយវិធីណាមួយ ដោយមិនគិតថា ការកែប្រែនោះត្រូវបានចុះហត្ថលេខាអមដោយបហារីកឡើយ ។ ការដាក់ប្រាក់បញ្ញើដែលជាមូលប្បទានប័ត្រទាំងអស់ត្រូវបានទទួលដោយធនាគារ ព្រីនស៍ ម.ក ក្នុងនាមជាភ្នាក់ងារសម្រាប់បេឡានិច្ច័យ។ ធនាគារ ព្រីនស៍ ម.ក អាចដំណើរការមូលប្បទានប័ត្រ ទោះជាមានភាពខុសគ្នារវាង ឈ្មោះរបស់អត្ថគាហកកំណត់នៅក្នុងមូលប្បទានប័ត្រ ប្រៀបធៀបទៅនឹងឈ្មោះ**គណនី**របស់**អតិថិជន**ក៏ដោយ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ មូលប្បទានប័ត្រដែលត្រូវបានបដិសេធ អាចត្រូវបានបញ្ជូនត្រឡប់ទៅ**អតិថិជន**វិញតាមប្រៃសណីយ៍ តាមរយៈអាសយដ្ឋានចុងក្រោយដែលបានផ្តល់ឱ្យធនាគារតាមហានិភ័យ និងការចំណាយផ្ទាល់របស់**អតិថិជន**។

៤. ធនាគារ ព្រីនស៍ ម.ក យល់ព្រមជាមួយធនាគារដំទៃ ឬសភាផាត់ទាត់ ដើម្បីកែប្រែនីតិវិធីនិងពេលវេលា ទាក់ទងនឹងការធ្វើបេឡានិច័យមូលប្បទានប័ត្រដែលត្រូវបានបញ្ជូនទៅវិញ ឬ វត្ថុណាមួយផ្សេងទៀត។ ធនាគារ ព្រីនស៍ ម.ក មិនត្រូវ ហើយនឹងមិនទទួលខុសត្រូវលើសកម្មភាពធ្វើឡើងដោយធនាគារដំទៃ (ឬភ្នាក់ងាររបស់ពួកគេ) ឬសភាផាត់ទាត់ ឬលើការបាត់បង់ ឬការបំផ្លាញនូវវត្ថុណាមួយ ក្រោមការកាន់កាប់របស់ធនាគារនោះ ឬសភាផាត់ទាត់នោះ ឬនៅក្នុងពេលដឹកជញ្ជូនឡើយ។ **អតិថិជន**យល់ព្រមចាត់វិធានការសមស្របដើម្បីជួយសម្រួលដល់ធនាគារ ព្រីនស៍ ម.ក ក្នុងការស្វែងរក ឬការទទួលនូវវត្ថុជំនួស ដែលបានបាត់បង់នៅក្នុងពេលកាន់កាប់ដោយធនាគារ ព្រីនស៍ ម.ក។

គ. ទាក់ទងនឹងមូលនិធិ ដែល ធនាគារ ព្រីនស៍ ម.កទទួលបានសម្រាប់**គណនី**របស់**អតិថិជន**៖

១. លើកលែងតែមានការជូនដំណឹងផ្សេងពីនេះដោយធនាគារ ព្រីនស៍ ម.ក ទៅ**អតិថិជន** មូលនិធិណាមួយនោះអាចត្រូវដកយកទៅប្រើប្រាស់បានដោយ**អតិថិជន** ស្របតាមគោលនយោបាយ និងការអនុវត្តជាទូទៅ លើការទទួលមូលនិធិរបស់ធនាគារ ព្រីនស៍ ម.ក។

២. ប្រសិនបើ**អតិថិជន បញ្ជា**ឱ្យធនាគារ ព្រីនស៍ ម.ក ធ្វើការដាក់ប្រាក់បញ្ញើចូលក្នុង**គណនី**ណាមួយ ហើយមូលនិធិដែលត្រូវបានទទួលដោយធនាគារ ព្រីនស៍ ម.ក ជារូបិយប័ណ្ណដែលខុសពីរូបិយប័ណ្ណរបស់**គណនី**នោះ ធនាគារ ព្រីនស៍ ម.ក ត្រូវប្តូរចំនួនដែលទទួលបានទៅជារូបិយប័ណ្ណរបស់**គណនី**នោះទៅតាម**អត្រាដែលត្រូវអនុវត្ត**។

៤.៣. ការដកប្រាក់ និងការទូទាត់៖

ក. ទាក់ទងនឹងការដកប្រាក់ពី**គណនី** ឬការ**បញ្ជា**ទូទាត់ប្រាក់ដោយ**អតិថិជន**៖

១. ការដកប្រាក់ទាំងអស់ត្រូវភ្ជាប់មកជាមួយនឹងប័ណ្ណដាក់ប្រាក់បញ្ញើដែលកំណត់ ការបង្ហាញសៀវភៅប្រាក់បញ្ញើសំចៃ ឬទម្រង់ណាមួយផ្សេងទៀតនៃអត្តសញ្ញាណ និងជាកម្មវត្ថុនៃការ

បង្ហាញភស្តុតាងអត្តសញ្ញាណ ដែលធ្វើឡើងតាមការតម្រូវរបស់ ធនាគារ ព្រីនស៍ ម.ក ហើយ ធនាគារ ព្រីនស៍ ម.ក អនុញ្ញាតឱ្យធ្វើការដកប្រាក់ពី**គណនី**នោះ តាមការកម្រិតដែលបានយល់ព្រម ឬកំណត់ដោយធនាគារ ព្រីនស៍ ម.ក៖

ក. ប្រសិនបើ**អតិថិជន** មាន**មូលនិធិច្បាស់លាស់**នៅក្នុង**គណនី**នោះ យ៉ាងតិចស្មើនឹងចំនួនទឹកប្រាក់ដែលត្រូវបានដក ដូចដែលបានកំណត់យ៉ាងច្បាស់ដោយ**អតិថិជន**។ និង

ខ. ប្រសិនបើការដកប្រាក់ រួមបញ្ចូលទាំង**បញ្ជា**ណាមួយ ដែលត្រូវបានបំពេញត្រឹមត្រូវ គោរពតាម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់ របស់**គណនីចរន្ត និងគណនីបញ្ញើសំចៃ (CASA) និង **បញ្ញត្តិ និងលក្ខខណ្ឌ**ប្រាក់បញ្ញើមានកាលកំណត់។

២. រាល់ការដកប្រាក់តាមរយៈម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ("អេធីអឹម") ត្រូវធ្វើឡើងស្របតាម **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** សម្រាប់គ្រប់គ្រងអេធីអឹម ដែលបានដាក់ឱ្យត្រូវអនុវត្ត។

ខ. បញ្ជា

១. ធនាគារ ព្រីនស៍ ម.ក អនុវត្តបញ្ជានៅកាលបរិច្ឆេទទូទាត់ប្រាក់ ដែលកំណត់ដោយ**អតិថិជន** ក្នុងលក្ខខណ្ឌ៖

ក. បញ្ជានោះត្រូវបានទទួលយ៉ាងត្រឹមត្រូវដោយធនាគារ ព្រីនស៍ ម.ក មុនពេលវេលាកំណត់ (Cut-Off Time) ដែលពាក់ព័ន្ធ។

ខ. ការទូទាត់ប្រាក់ ត្រូវស្ថិតក្នុងកម្រិតអនុវត្តណាមួយ ដែលកំណត់ដោយធនាគារ ព្រីនស៍ ម.ក ឬក្នុងកម្រិត ឬកម្រិតអនុញ្ញាត កំណត់ដោយ**អតិថិជន** (ប្រសិនបើមានប្តូរទៅជារូបិយប័ណ្ណពាក់ព័ន្ធតាមអត្រាដែលត្រូវអនុវត្ត)។ និង

គ. **គណនី** មានមូលនិធិគ្រប់គ្រាន់ ឬការរៀបចំឥណទានគ្រប់គ្រាន់រួចរាល់ ដើម្បីធ្វើការទូទាត់ដូចបានបញ្ជាក់ក្នុង**បញ្ជា**។

២. ប្រសិនបើបញ្ជាត្រូវបានទទួល ឬ បញ្ជាក់កាលបរិច្ឆេទទូទាត់ប្រាក់ នៅថ្ងៃមិនមែនជា**ថ្ងៃធ្វើប្រតិបត្តិការអាជីវកម្ម** ការទូទាត់ប្រាក់នោះត្រូវចាប់ផ្តើមអនុវត្តនៅ**ថ្ងៃធ្វើប្រតិបត្តិការអាជីវកម្ម**បន្ទាប់ លើកលែងតែបានយល់ព្រមគ្នាផ្សេងពីនេះ រវាងធនាគារ ព្រីនស៍ ម.ក និង**អតិថិជន**។

៣. នៅពេលទទួលបាន**បញ្ជា** ធនាគារ ព្រីនស៍ ម.ក ត្រូវបានអនុញ្ញាតឱ្យធ្វើឥណពន្ធលើ**គណនី**ពាក់ព័ន្ធលើចំនួនទឹកប្រាក់សម្រាប់ការទូទាត់ និងធ្វើការដកនូវកម្រៃជើងសារ កម្រៃសេវាសោហ៊ុយ និងចំណាយពាក់ព័ន្ធនានា។

៤. លើកលែងតែបានបញ្ជាក់ដោយ**អតិថិជន**នៅក្នុង**បញ្ជា**ណាមួយ ធនាគារ ព្រីនស៍ ម.ក អាចកំណត់អាទិភាពនៃការទូទាត់ប្រាក់ក្នុង**បញ្ជា**ណាមួយ។

៥. ទោះបីជាមាន**បញ្ជា**ណាមួយពី**អតិថិជន**ផ្ទុយពីនេះ ធនាគារ ព្រីនស៍ ម.ក រក្សាសិទ្ធិក្នុងការប្រើប្រាស់**តតិយជន** ក្នុងការអនុវត្ត**បញ្ជា**លើការផ្ទេរមូលនិធិ ហើយអាចប្រើប្រាស់មធ្យោបាយណា

មួយក្នុងការអនុវត្ត**បញ្ជា**លើការផ្ទេរមូលនិធិនោះ ដែលធនាគារ ព្រីនស៍ ម.ក ចាត់ទុកថាសមរម្យ ក្នុងកាលៈទេសៈនោះ។

៦. **អតិថិជន**ប្រកាស និងសន្យាចំពោះធនាគារ ព្រីនស៍ ម.ក ថា ការទូទាត់ដែលបានធ្វើឡើងដោយធនាគារ ព្រីនស៍ ម.ក ស្របតាម**បញ្ជា**ណាមួយ នឹងមិនបំពានច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ការដាក់ទណ្ឌកម្ម ឬការតម្រូវរបស់**អាជ្ញាធរ**មានសមត្ថកិច្ចណាមួយ ឬលក្ខខណ្ឌណាមួយ នៃបញ្ញត្តិ និង **លក្ខខណ្ឌទូទៅ** ព្រមទាំង បញ្ញត្តិ និង**លក្ខខណ្ឌជាក់លាក់**ពាក់ព័ន្ធណាមួយផ្សេងទៀត ហើយមិនអនុញ្ញាតឱ្យ**អតិថិជន**ធ្វើការទូទាត់ប្រាក់ សម្រាប់គោលបំណងខុសច្បាប់ ឬក្លែងបន្លំណាមួយឡើយ។

៧. នៅពេលធនាគារ ព្រីនស៍ ម.ក បានយល់ព្រមទទួលយក**បញ្ជា**លើការទូទាត់ប្រាក់មុនកាលបរិច្ឆេទកំណត់ **អតិថិជន**ទទួលស្គាល់ និងយល់ព្រមថា រាល់ការទូទាត់ដែលបានធ្វើឡើងនៅមុនកាលបរិច្ឆេទកំណត់ ដែលបញ្ជូនមកដោយ**អតិថិជន** នឹងត្រូវធ្វើឡើងសម្រាប់តម្លៃនៅថ្ងៃដែលធនាគារ ព្រីនស៍ ម.ក ទទួលបាន ឬនៅថ្ងៃធ្វើប្រតិបត្តិការអាជីវកម្មបន្ទាប់ ប្រសិនបើ**បញ្ជា**ត្រូវបានទទួលបន្ទាប់ពី**ពេលវេលាកំណត់** (Cut-Off Time) ។ ការទូទាត់នឹងមិនត្រូវធ្វើឡើងសម្រាប់តម្លៃ នៅកាលបរិច្ឆេទពីមុន ដែលបានកំណត់ក្នុង**បញ្ជា**ឱ្យធ្វើការទូទាត់ឡើយ។

៨. **សេវាកម្ម**ណាមួយពាក់ព័ន្ធនឹង**គណនី** ជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ត្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនោះផ្តល់ព័ត៌មានតម្រូវ ឬអនុវត្តការ**បញ្ជា**ផ្ទេរពីធនាគារ ព្រីនស៍ ម.ក ក្នុងរយៈពេលដែលបានតម្រូវឱ្យ។

គ. ការត្រួតពិនិត្យ និងការរាប់សាច់ប្រាក់

១. **អតិថិជន**ត្រូវធ្វើការត្រួតពិនិត្យ និងរាប់សាច់ប្រាក់ ភ្លាមៗតាមដែលអាចធ្វើបាន នៅចំពោះមុខបុគ្គលិកដែលបានចាត់តាំងដោយធនាគារ ព្រីនស៍ ម.ក និងត្រួតពិនិត្យព័ត៌មានផ្សេងទៀតមុននឹងចាកចេញពីបញ្ជររបស់ធនាគារ ព្រីនស៍ ម.ក។

២. **អតិថិជន**ត្រូវត្រួតពិនិត្យរាល់ព័ត៌មានលម្អិតសម្រាប់ការទូទាត់ប្រាក់ទាំងអស់ ឱ្យបានច្បាស់លាស់ មុននឹងស្នើសុំ**សេវាកម្ម**ណាមួយ។

៣. ការដកប្រាក់ និងការទូទាត់ប្រាក់ពី**គណនី**ជាក់លាក់ ត្រូវពឹងផ្អែកលើរបៀបប្រតិបត្តិការរបស់**គណនី**ជាក់លាក់នោះ ដែលបានកំណត់ដោយ**អតិថិជន**លើវិធាន នៃការធ្វើប្រតិបត្តិការ**គណនី**។ និង

៤. ប្រសិនបើមានការកែប្រែលើវិធាន និង/ឬ របៀបនៃការធ្វើប្រតិបត្តិការ**គណនី**នៅពេលណាមួយនាពេលអនាគត **អតិថិជន**ត្រូវធ្វើការស្នើសុំទៅធនាគារ ព្រីនស៍ ម.ក ជាលាយលក្ខណ៍អក្សរក្នុងទម្រង់បែបបទដែលបានកំណត់។

៤.៤. គណនីមិនដំណើរការ៖ **គណនី** ដែលសកម្មភាពប្រតិបត្តិការមិនបានកើតឡើងក្នុងរយៈពេលជាក់លាក់ណាមួយដែលបានកំណត់ដោយច្បាប់ជាធរមាន ត្រូវចាត់ទុកថាជាគណនីមិនដំណើរការ

(គណនីអកម្ម) ("**គណនីមិនប្រើ**") ហើយកម្រៃសេវានឹងត្រូវបានកាត់ដោយផ្ទាល់ពីគណនីនោះ ដូចបានកំណត់ដោយធនាគារ ព្រីនស៍ ម.ក។ សមតុល្យឥណទានរបស់គណនីមិនដំណើរការនៅធនាគារ ព្រីនស៍ ម.ក ត្រូវបញ្ជូនទៅ **ធនាគារជាតិ**។

៤.៥. គណនីបង្កក៖ ធនាគារ ព្រីនស៍ ម.ក មានសិទ្ធិ បញ្ឈប់ការផ្តល់សុពលភាព ឬអនុវត្តលើប្រតិបត្តិការណាមួយរួមមានដោយមិនកម្រិតត្រឹមតែការដកប្រាក់ ការផ្ទេរប្រាក់ ឬការទូទាត់ប្រាក់ ឬឧបករណ៍ផ្សេងៗ ឬ**បញ្ជា**ណាមួយតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនចាំបាច់ជូនដំណឹងជាមុនទៅអតិថិជនដើម្បីអនុវត្តការទូទាត់ប្រាក់នៅក្នុងគណនីបង្កកនានា ("**គណនីបង្កក**") នៅពេលដែលមានព្រឹត្តិការណ៍ខាងក្រោមណាមួយបានកើតឡើង៖

ក. ធនាគារ ព្រីនស៍ ម.ក បានទទួលការស្នើសុំពី**អាជ្ញាធរ**មានសមត្ថកិច្ច រួមមានដោយមិនកម្រិតត្រឹមតែ**ធនាគារជាតិ** ឬតុលាការក្នុងការបង្កក**គណនី** ដោយមិនគិតថា**អាជ្ញាធរ**មានសមត្ថកិច្ចនោះ មានអំណាចស្របច្បាប់ ឬត្រឹមត្រូវក្នុងការស្នើសុំទៅ ធនាគារ ព្រីនស៍ ម.ក។

ខ. ធនាគារ ព្រីនស៍ ម.ក បានទទួលការជូនដំណឹងពីសកម្មភាពក្ស័យធន និង/ឬ បណ្តឹងបញ្ចប់សកម្មភាព ឬការក្ស័យធនត្រូវបានបង្ហាញ។

គ. ធនាគារ ព្រីនស៍ ម.ក ទទួលដំណឹងអំពីការទាមទារប្រឆាំង ជំទាស់ ឬជម្លោះ ដោយអភិបាលឬម្ចាស់ភាគហ៊ុន ឬអ្នកកាន់កាប់គណនីរួមផ្សេងទៀត ឬដោយបុគ្គលដែលចោទប្រកាន់ថាជាអភិបាល ឬម្ចាស់ភាគហ៊ុន ឬអ្នកកាន់កាប់គណនីរួមផ្សេងទៀត ទាក់ទងនឹង**គណនី**ណាមួយ។

## ៥. ការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងការគ្រប់គ្រងការដាក់ទណ្ឌកម្ម

៥.១. ទោះបីជាមានប្រការផ្សេងណាមួយផ្ទុយពីនេះនៅក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ធនាគារ ព្រីនស៍ ម.ក មិនត្រូវមានកាតព្វកិច្ចធ្វើ ឬលុបចោលអ្វីមួយ ប្រសិនបើខ្លួនត្រូវធ្វើ ឬ ដោយការយល់ឃើញសមស្រប វានឹងបង្កើតឱ្យមានការបំពានលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន ស្តីពីការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ឬទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដែលអនុវត្តចំពោះធនាគារ ព្រីនស៍ ម.ក ។

៥.២. **អតិថិជន**ត្រូវផ្តល់ជូនទៅធនាគារ ព្រីនស៍ ម.ក ឱ្យបានឆាប់រហ័សនូវព័ត៌មាន និងឯកសារទាំងអស់ដែលស្ថិតក្នុងការកាន់កាប់ រក្សាទុក ឬការគ្រប់គ្រងរបស់ខ្លួន ដែលបានតម្រូវយ៉ាងសមហេតុផលដោយធនាគារ ព្រីនស៍ ម.ក ដើម្បីឱ្យធនាគារ ព្រីនស៍ ម.ក គោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានស្តីពីការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ឬទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្មដែលអនុវត្តចំពោះធនាគារ ព្រីនស៍ ម.ក ។

៥.៣. **អតិថិជន**យល់ព្រមថា ធនាគារ ព្រីនស៍ ម.ក អាចបញ្ចេញព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹង**អតិថិជន** និង**គណនី**របស់**អតិថិជន**ទៅ**អាជ្ញាធរ** តាមការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលអនុវត្តចំពោះធនាគារ ព្រីនស៍ ម.ក ។

៥.៤. **អតិថិជន**យល់ព្រមអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធនានាផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ស្តីពីការប្រឆាំងការសម្អាតប្រាក់ ការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ឬទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដែលអនុវត្តចំពោះធនាគារ ព្រីនស៍ ម.ក ។

៥.៥. **អតិថិជន**ប្រកាសថា អតិថិជនកំពុងធ្វើសកម្មភាពសម្រាប់ខ្លួនឯងផ្ទាល់ និងមិនមែនធ្វើសម្រាប់ អ្នកទទួលអាណត្តិព្យាបាល ឬភ្នាក់ងារឡើយ លើកលែងតែបានបង្ហាញយ៉ាងច្បាស់លាស់ទៅធនាគារ ព្រីនស៍ ម.ក។

## ៦. របាយការណ៍គណនី យោបល់បញ្ជាក់ និងសេវាកម្មធ្វើរបាយការណ៍

៦.១. របាយការណ៍**គណនី** ប័ណ្ណប្រតិបត្តិការ ឬរបាយការណ៍ (បើទោះជាក្នុងទម្រង់ក្រដាស ឬតាមរយៈមធ្យោបាយផ្សេងទៀត) អាចត្រូវបានផ្តល់ជូន**អតិថិជន** (ដូចបានយល់ព្រមជាមួយ**អតិថិជន**) ឬ អាចឱ្យ**អតិថិជនប្រើប្រាស់** ជាប្រចាំខែ ឬក្នុងអំឡុងពេលដែលធនាគារ ព្រីនស៍ ម.ក យល់ព្រមជាមួយ**អតិថិជន**។

៦.២. **អតិថិជន** ត្រូវផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវ និងភាពសុក្រឹតនៃរបាយការណ៍**គណនី**ទាំងអស់ ដែលបានផ្តល់ជូន ការឱ្យយោបល់បញ្ជាក់ ឬរបាយការណ៍ ដែលទទួលបានពីធនាគារ ព្រីនស៍ ម.ក លើកលែងតែ**អតិថិជន**ជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៥ (ប្រាំ) **ថ្ងៃនៃថ្ងៃធ្វើប្រតិបត្តិការអាជីវកម្ម** នៃកាលបរិច្ឆេទលើរបាយការណ៍**គណនី** ឬយោបល់បញ្ជាក់នីមួយៗ អំពីកំហុស ភាពមិនប្រក្រតី ការបាត់ព័ត៌មាន ភាពមិនសុក្រឹត ឬភាពមិនស៊ីសង្វាក់គ្នា ក្នុងកំណត់ត្រានានា នោះកំណត់ត្រាទាំងនោះត្រូវចាត់ទុកថាត្រឹមត្រូវ សុក្រឹត និងត្រូវទុកជាស្ថាពរ និងចងភ្ជាប់កាតព្វកិច្ច។

៦.៣. ដោយមិនប៉ះពាល់ចំពោះប្រការ ៦.២ ខាងលើ ធនាគារ ព្រីនស៍ ម.ក អាចធ្វើការកែតម្រូវគ្រប់ពេលនូវកំហុសឬការបាត់ព័ត៌មាន ក្នុងរបាយការណ៍**គណនី** ប័ណ្ណប្រតិបត្តិការ ឬ របាយការណ៍ណាមួយដែលត្រូវចាត់ទុកថាស្ថាពរ និងចងភ្ជាប់កាតព្វកិច្ចចំពោះ**អតិថិជន** បន្ទាប់ពីបានកែតម្រូវរួច។ ធនាគារ ព្រីនស៍ ម.ក មានសិទ្ធិទាមទារប្រាក់សង និងធ្វើឥណពន្ធលើ**គណនី**ណាមួយសម្រាប់ ការទូទាត់ប្រាក់លើស ដែលកើតចេញពីកំហុស ឬការបាត់ព័ត៌មាននោះ។

៦.៤. របាយការណ៍ណាមួយដែលផ្តល់ដោយធនាគារ ព្រីនស៍ ម.ក ដែលបង្កើតឡើងដោយកុំព្យូទ័រ មិនត្រូវការហត្ថលេខាឡើយ ហើយនឹងត្រូវបកស្រាយដោយភ្ជាប់ជាមួយនឹងរបាយការណ៍**គណនី**ពាក់ព័ន្ធ។

## ៧. កម្រៃជើងសារ កម្រៃសេវា សោហ៊ុយ ចំណាយ និងពន្ធ

៧.១. **អតិថិជន**ត្រូវបង់ ដោយមិនត្រូវកាត់កង ដក ឬទាមទារមកវិញ នូវកម្រៃជើងសារ កម្រៃសេវា សោហ៊ុយនិងចំណាយទាំងអស់ ទាក់ទងនឹង**គណនី ផលិតផល** និង**សេវាកម្ម**នីមួយៗ ទៅតាមអត្រា និងពេលវេលា ដែលបានជូនដំណឹងដោយ ធនាគារ ព្រីនស៍ ម.ក ទៅកាន់**អតិថិជន** តាមដែលអាចអនុវត្តបានដូចមានកំណត់នៅក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ**ជាក់លាក់ បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់ស្តីពីអត្រា និងកម្រៃសេវាស្តង់ដារ ឬទម្រង់ផ្សេងៗ។

៧.២. លើកលែងតែមានការយល់ព្រមផ្សេងពីនេះជាមួយនឹងធនាគារ ព្រីនស៍ ម.ក មិនមានវិក្កយប័ត្រ សម្រាប់កម្រៃជើងសារ កម្រៃសេវា សោហ៊ុយ និងចំណាយណាមួយឡើយដែលនឹងត្រូវផ្តល់ជូន ហើយរាល់ចំនួនទឹកប្រាក់ដែលអតិថិជនបានជំពាក់ អាចត្រូវធ្វើឥណពន្ធពី**គណនី** ដោយមិនគិតថា ការធ្វើឥណពន្ធនោះនឹងធ្វើឱ្យមានការកើនឡើងនូវសមតុល្យឥណពន្ធក្នុង**គណនី**ពាក់ព័ន្ធ។

៧.៣. រាល់កម្រៃជើងសារ កម្រៃសេវា សោហ៊ុយ និងចំណាយ ដែលត្រូវដកចេញពី**គណនី** ត្រូវតែបង្ហាញក្នុងរបាយការណ៍**គណនី**ពាក់ព័ន្ធ។

៧.៤. **អតិថិជន**ត្រូវបង់**ពន្ធទាំងអស់**ដែលត្រូវអនុវត្តចំពោះខ្លួន និងដែលត្រូវបង់ ពាក់ព័ន្ធនឹង**គណនី** ឬ**សេវាកម្ម**ណាមួយ តាមករណីអនុវត្តជាក់ស្តែង ធនាគារ ព្រីនស៍ ម.ក អាចធ្វើឥណពន្ធលើ**ពន្ធ**នោះពី**គណនីរបស់អតិថិជន**នៅពេលដែលអតិតិជនត្រូវបង់កម្រៃជើងសារ កម្រៃសេវា សោហ៊ុយ និងចំណាយ។

៧.៥. តាមរយៈការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ឬកិច្ចព្រមព្រៀង ឬការរៀបចំរបស់**អាជ្ញាធរ**ក្នុងស្រុក ឬបរទេសណាមួយ ធនាគារ ព្រីនស៍ ម.ក អាចដក ឬកាត់ទុកពីការទូទាត់ដែលធ្វើឡើងជាមួយ**អតិថិជន**ពាក់ព័ន្ធនឹង**គណនី**របស់ពួកគេ។ នៅពេលដែលមានការតម្រូវឱ្យធនាគារ ព្រីនស៍ ម.ក ឱ្យធ្វើការដក ឬកាត់ទុកនូវការទូទាត់ណាមួយ **អតិថិជន** ទទួលស្គាល់ និងយល់ព្រមថា ការទូទាត់ពាក់ព័ន្ធផ្សេងៗនឹងត្រូវបន្ថយតាមចំនួននៃការដក ឬការកាត់ទុកនោះ។

៧.៦. ប្រសិនបើមានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានសម្រាប់អតិថិជនដើម្បីធ្វើការដក ឬកាត់ទុកចំពោះ ឬនៅលើគណនី**ពន្ធ** នោះចំនួនសរុបអតិថិជនត្រូវបង់ទៅធនាគារ ព្រីនស៍ ម.ក (ទោះក្នុងករណី ការដកនោះត្រូវបានតម្រូវឱ្យធ្វើឡើង) ត្រូវបង្កើនរហូតដល់ចំនួនចាំបាច់ក្នុងការធានាថា ធនាគារ ព្រីនស៍ ម.ក ទទួលប្រាក់សរុបសុទ្ធពីការដក ឬការកាត់ទុកណាមួយ ស្មើនឹងចំនួនសរុបដែលខ្លួននឹងត្រូវបានទទួល នៅពេលដែលគ្មានការដកកើតឡើង ឬតម្រូវឱ្យកើតឡើង ។ **អតិថិជន** ត្រូវដក និងធ្វើការទូទាត់ណាមួយដែលបានតម្រូវ ពាក់ព័ន្ធនឹងការដកនោះ ក្នុងរយៈពេលដែលបានអនុញ្ញាត និងក្នុងចំនួនអតិប្បរមាតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ៨. ការបញ្ចប់ និងការព្យួរ

៨.១ ធនាគារ ព្រីនស៍ ម.ក អាចបញ្ឈប់**គណនី** ឬ**សេវាកម្ម** ដោយមានប្រសិទ្ធភាពអនុវត្តភ្លាម និងមិនចាំបាច់មានការជូនដំណឹងជាមុនៈ

ក. ប្រសិនបើ ធនាគារ ព្រីនស៍ ម.ក យល់ឃើញថា ការធ្វើសកម្មភាពក្រោម**បញ្ជា**របស់**អតិថិជន** ឬការផ្តល់**គណនី** ឬ**សេវាកម្ម**ទៅ**អតិថិជន** ធ្វើឱ្យធនាគារ ព្រីនស៍ ម.ក ប្រឈមមុខនឹងការរំលោភបំពានច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ទណ្ឌកម្ម ឬការតម្រូវផ្សេងទៀតពី**អាជ្ញាធរ**មានសមត្ថកិច្ច។

ខ. ប្រសិនជាលក្ខខណ្ឌតម្រូវសម្រាប់ធនាគារ ព្រីនស៍ ម.ក ឱ្យធ្វើបែបនោះ ដើម្បីអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលកំពុងអនុវត្ត នៅព្រះរាជាណាចក្រកម្ពុជា ទណ្ឌកម្ម ឬការតម្រូវផ្សេងទៀតពី**អាជ្ញាធរ**មានសមត្ថកិច្ច ឬបទបញ្ជាផ្ទៃក្នុងរបស់ធនាគារ ព្រីនស៍ ម.ក។ ឬ

គ. ក្នុងករណី**តតិយជន**ឈប់ផ្តល់សេវាកម្មផ្នែកណាមួយ។ ចំពោះការបញ្ឈប់នេះ កាតព្វកិច្ចណាមួយដែល**អតិថិជន**មានចំពោះធនាគារ ព្រីនស៍ ម.ក ត្រូវដល់កំណត់សង និងត្រូវបង់ភ្លាមៗ។

៨.២. ធនាគារ ព្រីនស៍ ម.ក អាចព្យួរ**គណនី ផលិតផល** ឬ**សេវាកម្ម** មួយផ្នែក ឬទាំងស្រុង (ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនក្រោមប្រការ ៨.១) ដោយហេតុផលណាមួយ ដោយមិនចាំបាច់មានការជូនដំណឹងជាមុនទៅ**អតិថិជន** រួមមានជាអាទិ៍ នៅពេលដែលៈ

ក. **គណនី** ឬការផ្តល់**ផលិតផល** ឬ**សេវាកម្ម** ជាកម្មវត្ថុនៃជម្លោះ ឬការទាមទាររបស់**តតិយជន**។

ខ. ធនាគារ ព្រីនស៍ ម.ក ចាត់ទុកថា មិនមានសមតុល្យក្នុង**គណនី**គ្រប់គ្រាន់។

គ. ធនាគារ ព្រីនស៍ ម.ក ចាត់ទុកថា ជាការចាំបាច់ក្នុងការការពារផលប្រយោជន៍របស់ភាគីណាមួយទាក់ទងនឹង**គណនី** ឬការផ្តល់**ផលិតផល** ឬ**សេវាកម្ម**។

ឃ.ធនាគារ ព្រីនស៍ ម.ក ចាត់ទុកថា ជាការចាំបាច់ក្នុងការបញ្ជាក់ពីសិទ្ធិអំណាចរបស់**បុគ្គលដែលទទួលបានការអនុញ្ញាត**។

ង. ធនាគារ ព្រីនស៍ ម.ក ចាត់ទុកថា **គណនី ផលិតផល** ឬ**សេវាកម្ម** មិនត្រូវបានប្រើប្រាស់តាមវិធីសមស្រប។

ច. **តតិយជនឈប់**ផ្តល់សេវាកម្មផ្នែកណាមួយ។ ឬ

ឆ. ធនាគារ ព្រីនស៍ ម.ក ផ្តល់យោបល់ទៅ**អតិថិជន** ភ្លាមៗតាមដែលអាចអនុវត្តបាន ប្រសិនបើ**គណនី** ឬការផ្តល់**ផលិតផល** ឬ**សេវាកម្ម** ត្រូវបានព្យួរ តាមវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ និងបទបញ្ញត្តិជាធរមាន។

៨.៣. រាល់ការបញ្ចប់ ឬការព្យួរ**គណនី ផលិតផល** ឬ**សេវាកម្ម** មិនត្រូវមានការប៉ះពាល់ទៅដល់**បញ្ហាដែលមានស្រាប់**ឬសិទ្ធិ ឬកាតព្វកិច្ចដែលកើតមានរវាង ធនាគារ ព្រីនស៍ ម.ក និង**អតិថិជន** មុនពេលមានការបញ្ចប់នោះ ឬមានចែងក្នុងបញ្ញត្តិ និង **លក្ខខណ្ឌទូទៅ ដើម្បីបន្តការបញ្ចប់នូវបញ្ញត្តិ និងលក្ខខណ្ឌទូទៅ**។

៨.៤. នៅពេលបញ្ឈប់**គណនី**ៈ

ក. ធនាគារ ព្រីនស៍ ម.ក អាចធ្វើឥណពន្ធលើរាល់សោហ៊ុយ និងចំណាយទាំងអស់ ពាក់ព័ន្ធនឹងការបញ្ឈប់នោះ និងលើចំនួនដែល**អតិថិជន**ជំពាក់ធនាគារ ព្រីនស៍ ម.ក ក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង **បញ្ញត្តិ និង លក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធនានាផ្សេងទៀត។ និង

ខ. ប្រសិនបើសមតុល្យឥណទាននៅសល់ បន្ទាប់ពីធ្វើឥណពន្ធរួច ធនាគារ ព្រីនស៍ ម.ក អាច ផ្ទេរសមតុល្យឥណទាននោះ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន តាមមធ្យោបាយផ្ទេរប្រាក់ ដែលធនាគារ ព្រីនស៍ ម.ក ចាត់ទុកថាសមស្របទៅ**គណនី**នោះ (រួមបញ្ចូលទាំង**គណនី**ជាមួយនឹងសាខាមួយផ្សេងទៀតរបស់ធនាគារ ព្រីនស៍ ម.ក) តាមភាពសមស្រប ឬដោយមធ្យោបាយ របិយាណត្តិបង់

ទៅ**អតិថិជន** ផ្ញើតាមប្រៃសណីយ៍ទៅ**អតិថិជន**តាមអាសយដ្ឋាន ដែលបានដឹងចុងក្រោយ ស្រប តាមហានិភ័យ និងការចំណាយរបស់**អតិថិជន**ផ្ទាល់។

៨.៥. បទប្បញ្ញត្តិទាំងឡាយណា ដែលមានគោលបំណងឱ្យអតិថិជនបន្តគោរព និងអនុវត្តទោះបីបន្ទាប់ពី ការបញ្ឈប់ត្រូវបន្តសុពលភាពទោះបីបន្ទាប់ពីការបញ្ឈប់នូវគណនី ផលិតផល ឬ សេវាកម្ម ឬ បញ្ញត្តិ និងលក្ខខណ្ឌទូទៅនោះ។

## ៩. សំណងការខូចខាត

៩.១. ចំនួនទឹកប្រាក់នីមួយៗដែលអតិថិជនដល់កាលកំណត់សង និងត្រូវបង់ ទៅធនាគារ ព្រីនស៍ ម.ក ក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ព្រមទាំង**បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធនានាផ្សេងទៀត ត្រូវធ្វើឡើងតាម**រូបិយប័ណ្ណដែលបានព្រមព្រៀងរវាង** អតិថិជន និងធនាគារ ព្រីនស៍ ម.ក។ ប្រសិនបើ ក្នុងហេតុផលណាមួយ ចំនួនទឹកប្រាក់ដែលធនាគារ ព្រីនស៍ ម.ក ទទួលបាន (នៅពេលបម្លែងតាម **អត្រាដែលត្រូវអនុវត្ត**) តិចជាងចំនួនទឹកប្រាក់ក្នុងរូបិយប័ណ្ណ ដែលបានព្រមព្រៀង បង់ទៅធនាគារ ព្រីនស៍ ម.ក នោះ**អតិថិជន**ត្រូវទូទាត់ភ្លាមនូវចំនួនទឹកប្រាក់បន្ថែមក្នុងរូបិយប័ណ្ណ ដែលបានព្រម ព្រៀងតាមការចាំបាច់ ដើម្បីសងចំនួនប្រាក់ដែលខ្វះ ទៅតាមការអនុញ្ញាតដែលច្បាប់ និងបទប្បញ្ញត្តិ ជាធរមានកំណត់។

៩.២. **អតិថិជន** យល់ព្រមដោយគ្មានការកែប្រែ និងដោយគ្មានលក្ខខណ្ឌ ក្នុងការផ្តល់សំណងការខូចខាត ទៅ និង ធានាធនាគារ ព្រីនស៍ ម.ក និង អភិបាល មន្ត្រី បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ ធនាគារ ព្រីនស៍ ម.ក រួចផុត និងមិនទទួលរងរាល់បណ្តឹងទាមទារ ការទាមទារ បណ្តឹង បំណុល ការ ខូតខាត ចំណាយ ការបាត់បង់ ដែលទទួលរង កើតឡើង ឬកើតមាន ពាក់ព័ន្ធ ឬទាក់ទងនឹង (ក) ធនាគារ ព្រីនស៍ ម.ក ដែលបានផ្តល់**គណនី ផលិតផល** ឬ**សេវាកម្ម** ដល់**អតិថិជន** (ខ) ការប្រើប្រាស់ **គណនី ផលិតផល** ឬ**សេវាកម្ម**របស់**អតិថិជន** (គ) ការខកខានរបស់**អតិថិជន** ក្នុងការអនុវត្ត ឬគោរព កាតព្វកិច្ចណាមួយក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** ព្រមទាំង បញ្ញត្តិ និង**លក្ខខណ្ឌជាក់លាក់**ពាក់ ព័ន្ធនានាផ្សេងទៀត (ឃ) ការធ្វើសកម្មភាព ឬបដិសេធការធ្វើសកម្មភាពរបស់ធនាគារ ព្រីនស៍ ម.ក តាម**បញ្ជា**របស់**អតិថិជន** ឬតាម**បញ្ជា** ឬការស្នើសុំ ដែលធនាគារ ព្រីនស៍ ម.ក ជឿជាក់ថា បានផ្តល់ ឱ្យដោយ ឬក្នុងនាម**អតិថិជន**។ ដើម្បីជៀសវាងភាពមិនច្បាស់លាស់ ប្រាក់សំណងដែលបានលើក ឡើងខាងលើនេះនឹងរាប់បញ្ចូលដោយមិនកម្រិតត្រឹមតែ បំណុល**ពន្ធ** និងសមតុល្យមានឱនភាព និង ការខាតបង់ដែលមិនបានដឹងមុនក្នុង**គណនី**ណាមួយ។

៩.៣. ដោយមិនប៉ះពាល់ដល់ប្រការ ៩.២ **អតិថិជន** យល់ព្រមដោយគ្មានការកែប្រែ និងដោយគ្មាន លក្ខខណ្ឌ ក្នុងការផ្តល់សំណងការខូចខាត ទៅធនាគារ ព្រីនស៍ ម.ក និង អភិបាល មន្ត្រី បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ធនាគារ ព្រីនស៍ ម.ក រាល់ការខូចខាតទាំងអស់ ដែលធនាគារ ព្រីនស៍ ម.ក និងអភិបាល មន្ត្រី បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ធនាគារ ព្រីនស៍ ម.ក ទទួលរង កើត ឡើង ឬកើតមាន ពីលទ្ធផលនៃការធ្វើសកម្មភាពរបស់ធនាគារ ព្រីនស៍ ម.ក តាម**បញ្ជា**របស់ **អតិថិជន**។

៩.៤. ធនាគារ ព្រីនស៍ ម.ក អាចទូទាត់ភ្លាមៗនូវចំនួនទឹកប្រាក់ណាមួយ ឬទាំងអស់ ដែលត្រូវបានទាមទារពីធនាគារ ឬដែលធនាគារ ព្រីនស៍ ម.ក ក្លាយជាអ្នកទទួលខុសត្រូវសង ក្រោម ឬពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវសងប្រាក់របស់ធនាគារ ព្រីនស៍ ម.ក ដោយមិនចាំបាច់យោងទៅ ឬមានការអនុញ្ញាតបន្ថែម ពីម្ចាស់**គណនី** និងមិនចាំបាច់ត្រូវស្ថិតក្រោមភារកិច្ចណាមួយ ក្នុងការសួរនាំថាការទាមទារពីធនាគារ ព្រីនស៍ ម.ក នោះធ្វើឡើងត្រឹមត្រូវឡើយ ប្រសិនបើ ម្ចាស់**គណនី**បានបដិសេធទៅនឹងសុពលភាពនៃការទាមទារណាមួយ ហើយម្ចាស់**គណនី**ត្រូវទទួលយករាល់ការទាមទារពីធនាគារ ព្រីនស៍ ម.ក និងការទូទាត់នានា ដែលធនាគារ ព្រីនស៍ ម.ក ធ្វើឡើងដោយចងភ្ជាប់ជាកាតព្វកិច្ចដល់ម្ចាស់**គណនី**។ ចំនួនទឹកប្រាក់ដែលធនាគារ ព្រីនស៍ ម.ក បានបង់ ត្រូវធ្វើឥណពន្ធពី**គណនី** ដែលបានរក្សាដោយម្ចាស់**គណនី**ជាមួយនឹងធនាគារ ព្រីនស៍ ម.ក។

## ១០. ការកម្រិតលើការទទួលខុសត្រូវ

១០.១.ធនាគារ ព្រីនស៍ ម.ក មិនទទួលខុសត្រូវចំពោះ**អតិថិជន** លើការខូចខាតណាមួយដែលបានទទួលរង ឬកើតឡើង ឬដែលអាចនឹងកើតឡើងដោយផ្ទាល់ ឬប្រយោល ក្នុងរបៀបណាមួយនៃការកើតឡើងនោះ ឬក្នុងរបៀបណាមួយដែលពាក់ព័ន្ធនឹង**គណនី ផលិតផល** ឬ**សេវាកម្ម** លើកលែងតែវាជាការខូចខាតដោយផ្ទាល់ បង្កឡើងដោយការធ្វេសប្រហែស កំហុសដោយចេតនា ឬ ការលួចបន្លំ របស់ធនាគារ ព្រីនស៍ ម.ក នោះធនាគារ ព្រីនស៍ ម.ក ត្រូវទទួលខុសត្រូវចំពោះអតិថិជន។ ដោយមិនប៉ះពាល់ចំពោះប្រការខាងលើ ធនាគារ ព្រីនស៍ ម.ក នឹងមិនត្រូវទទួលខុសត្រូវ ទោះក្នុងកាលៈ ទេសៈណាក៏ដោយ ចំពោះ៖

ក. ការខូចខាតណាមួយដែលកើតឡើងដោយម្ចាស់**គណនី** ទាក់ទងនឹងការ កែប្រែព័ត៌មាន ដែលបានផ្តល់ទៅធនាគារ ព្រីនស៍ ម.ក ដែលមិនបានធ្វើការជូនដំណឹងត្រឹមត្រូវទៅធនាគារ ព្រីនស៍ ម.ក ។

ខ. ការបាត់បង់ទិន្នន័យ ឬអាជីវកម្ម ដែល**អតិថិជន** ឬភ្នាក់ងារអាចនឹងទទួលរង។

គ. រាល់ការរំខានដល់អាជីវកម្ម។

ឃ. ការបរាជ័យក្នុងការទទួលបានប្រាក់សន្សំដែលខ្លួនរំពឹងទុក។ ឬ

ង. ការបាត់បង់ណាមួយ ដែលជាផលវិបាក ដោយប្រយោល ជាពិសេស ដោយការពិន័យ ឬដោយយថាហេតុ។

១០.២.ដោយមិនប៉ះពាល់ចំពោះប្រការខាងលើ ធនាគារ ព្រីនស៍ ម.ក មិនទទួលខុសត្រូវ លើរាល់ការខូចខាតដែលបានកើតឡើង ឬមានចំពោះ**អតិថិជន** ដោយសារ**ព្រឹត្តិការណ៍ប្រធានសក្តិ**ឡើយ។ ប្រសិនបើ ជាលទ្ធផលរបស់**ព្រឹត្តិការណ៍ប្រធានសក្តិ** ធនាគារ ព្រីនស៍ ម.ក មិនអាច អនុវត្តកាតព្វកិច្ចរបស់ខ្លួនមួយផ្នែក ឬទាំងស្រុងក្រោម**បញ្ញត្តិ និង លក្ខខណ្ឌទូទៅ** ព្រមទាំង **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់** ពាក់ព័ន្ធនានាផ្សេងទៀត ឬផ្តល់ ឬរក្សា**គណនី ផលិតផល** ឬ**សេវាកម្ម** ហើយធនាគារ ព្រីនស៍ ម.ក នឹងព្យួរ**គណនី ផលិតផល** ឬ**សេវាកម្ម**ពាក់ព័ន្ធ រហូតដល់**ព្រឹត្តិការណ៍ប្រធានសក្តិ**ពាក់ព័ន្ធនានាបានបញ្ចប់ ដើម្បីអាចឱ្យការអនុវត្តលើគណនី ផលិតផល និងសេវាកម្មអាចធ្វើបាន

១០.៣.ធនាគារ ព្រីនស៍ ម.ក សន្មត់ថា មិនទទួលខុសត្រូវលើការធ្លាក់ចុះតម្លៃ នៃមូលនិធិក្នុង**គណនី**ណាមួយដោយហេតុផលណាមួយក៏ដោយ (ឧទាហរណ៍ ការប្រែប្រួលនៃអត្រាប្តូរប្រាក់ **ពន្ធ** ឬការរំលោះតម្លៃ) ឬការមិនអាចប្រើប្រាស់បាន នៃមូលនិធិនៅថ្ងៃដល់កំណត់សង ដោយសារ ការកម្រិតលើការបម្លែង ការតម្រូវ ការផ្ទេរដោយមិនស្ម័គ្រចិត្ត ការបញ្ឈប់បណ្តោះអាសន្ន ការគ្រប់គ្រងអត្រាប្តូរ ប្រាក់ ឬ **ព្រឹត្តិការណ៍ប្រធានសក្តិ**។

## ១១. ការទូទាត់កាត់កងប្រាក់

១១.១.នៅគ្រប់ពេលវេលា ធនាគារ ព្រីនស៍ ម.ក អាចទូទាត់កាត់កងប្រាក់ ចំពោះការទាមទារណាមួយដែលត្រូវបានទាមទារចំពោះធនាគារ ព្រីនស៍ ម.ក ជាមួយនឹងចំនួនទឹកប្រាក់ដែលត្រូវ ឬអាចនឹងត្រូវដល់ពេលកំណត់ត្រូវបង់ទៅធនាគារ ព្រីនស៍ ម.កនៅគ្រប់ពេល តាមការអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងដោយមិនចាំបាច់ជូនដំណឹងទៅអតិថិជន។

១១.២.សិទ្ធិបានចែងក្នុងប្រការ ១១.១ ខាងលើ អនុវត្តដោយមិនគិតទៅលើប្រភេទរូបិយប័ណ្ណ ដែលជាកម្មវត្ថុនៃការប្តឹងទាមទារការជំពាក់ឡើយ ហើយទោះបីជាការប្តឹងទាមទាររបស់ធនាគារ ព្រីនស៍ ម.ក ឬ **អតិថិជន** ស្ថិតក្នុងបច្ចុប្បន្ន ឬអនាគត ដល់ពេលសង ឬមិនទាន់ដល់ពេលសង ជាក់ស្តែង ឬយថាភូត និងទោះបីការទទួលខុសត្រូវនោះជាការទទួលខុសត្រូវរួមគ្នាជាមួយអ្នកផ្សេង ឬ ជាម្ចាស់សិទ្ធិ ឬជាអ្នកធានាក៏ដោយ។ នៅពេលការអនុវត្តសិទ្ធិក្នុងការទូទាត់មានពាក់ព័ន្ធនឹងការ បម្លែងរូបិយប័ណ្ណ ធនាគារ ព្រីនស៍ ម.ក ត្រូវអនុវត្តអត្រាប្តូររូបិយប័ណ្ណ ដែលធនាគារចាត់ទុកថាសមរម្យ។ ប្រសិនបើចំនួនទឹកប្រាក់នៃការប្តឹងទាមទារមិនទាន់បានកំណត់ ធនាគារ ព្រីនស៍ ម.ក អាចផ្តល់តម្លៃទៅលើការទាមទារនោះផ្អែកតាមភាពស្មោះត្រង់។

១១.៣.គ្មានបញ្ញត្តិណាមួយក្នុងប្រការ ១១ នេះ នឹងត្រូវមានប្រសិទ្ធភាពបង្កើតការដាក់បញ្ចាំ ឬសិទ្ធិប្រាតិភោគឡើយ។ ដោយមិនប៉ះពាល់ដល់ និងបន្ថែមពីលើសិទ្ធិនៃការទូទាត់កាត់កង ប្រការ ១១.៣ នេះ អាចទូទាត់កាត់កង ការបញ្ចូល**គណនី**រួមគ្នា ឯកសិទ្ធិ សិទ្ធិឃាត់ទុក ឬសិទ្ធិកាត់ទុក ឬសិទ្ធិប្រហាក់ប្រហែល ឬការតម្រូវដែលភាគីណាមួយមានសិទ្ធិ ឬអនុលោមតាម នៅពេលណាមួយ (ទោះបីជាដោយការអនុវត្ត ច្បាប់ កិច្ចសន្យា ឬផ្សេងពីនេះ)។

## ១២. ការបង្ហាញព័ត៌មាន

**អតិថិជន** យល់ព្រម និងទទួលស្គាល់ថា ធនាគារ ព្រីនស៍ ម.ក ត្រូវបានអនុញ្ញាតក្នុងការបង្ហាញនូវរាល់ព័ត៌មានទាក់ទងនឹង**អតិថិជន** (រួមមានជាអាទិ៍ ទាក់ទងនឹងប្រតិបត្តិការណាមួយរបស់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន **គណនី**របស់អតិថិជន) ទៅបុគ្គលណាមួយ ឬទាំងអស់ដូចខាងក្រោម៖

ក. អនុប្បទានិកជាក់លាក់ ឬតាមការស្នើសុំណាមួយ របស់ធនាគារ ព្រីនស៍ ម.ក ឬ អ្នកទទួលសិទ្ធិចំបង ឬ អ្នកទទួលសិទ្ធិដទៃផ្សេងទៀត នៃរាល់សិទ្ធិណាមួយ ទាក់ទងនឹង**អតិថិជន** ក្រោមកាតព្វកិច្ចរក្សាការសម្ងាត់ ចំពោះធនាគារ ព្រីនស៍ ម.ក។

ខ. ការិយាល័យ សាខា បុត្រសម្ព័ន្ធ បុគ្គលិក ឬភ្នាក់ងារណាមួយរបស់ធនាគារ ព្រីនស៍ ម.ក។

គ. សវនករ ឬទីប្រឹក្សាវិជ្ជាជីវៈណាមួយ របស់ធនាគារ ព្រីនស៍ ម.ក ក្រោមកាតព្វកិច្ចរក្សាការសម្ងាត់ចំពោះធនាគារ ព្រីនស៍ ម.ក។

ឃ.តតិយជនដែលជាក្រុមហ៊ុនផ្តល់សេវាកម្មដល់ធនាគារ ព្រីនស៍ ម.ក ។

ង. **អាជ្ញាធរ**មានសមត្ថកិច្ចណាមួយដែលពាក់ព័ន្ធ។

ច. បុគ្គលណាមួយ ដែលតម្រូវឱ្យបង្ហាញព័ត៌មាន ស្របតាមនីតិវិធីតុលាការរបស់យុត្តាធិការអនុវត្តពាក់ព័ន្ធ។ និង

ឆ.បុគ្គលណាមួយដែលតម្រូវឱ្យបង្ហាញព័ត៌មានស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ និង

ជ. **អាជ្ញាធរ**ក្នុងស្រុក ឬបរទេស ដែល មានកិច្ចព្រមព្រៀង ឬការសម្របសម្រួលណាមួយជាមួយធនាគារ ព្រីនស៍ ម.ក តម្រូវឱ្យបង្ហាញព័ត៌មានរបស់**អតិថិជន** ឬ**គណនី** ទោះការបង្ហាញនោះត្រូវធ្វើឡើងដោយធនាគារ ព្រីនស៍ ម.ក ផ្ទាល់ក៏ដោយ។

## ១៣. ការបោះបង់សិទ្ធិ

ការបោះបង់សិទ្ធិ ឬអំណាចណាមួយរបស់ធនាគារ ព្រីនស៍ ម.ក និងដោយមានការយល់ព្រមពីធនាគារ ព្រីនស៍ ម.ក ត្រូវមានសុពលភាព ក្នុងករណីបានចុះហត្ថលេខាក្នុងនាម ធនាគារ ព្រីនស៍ ម.ក ជាលាយលក្ខណ៍អក្សរស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។ ការបោះបង់សិទ្ធិ និងការយល់ព្រមនេះ ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិផ្តាច់មុខរបស់ធនាគារ ព្រីនស៍ ម.ក ។

## ១៤. ការផ្ទេរសិទ្ធិ

១៤.១.**អតិថិជន** មិនអាចផ្ទេរ ឬអនុប្បទាន សិទ្ធិ និងកាតព្វកិច្ចណាមួយរបស់ខ្លួនក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារ ព្រីនស៍ ម.ក នោះទេ។

១៤.២.**អតិថិជន** យល់ព្រមថា ធនាគារ ព្រីនស៍ ម.ក អាចធ្វើអនុប្បទាន នវកម្ម ផ្ទេរ ឬចាត់ចែងផ្សេងពីនេះនូវរាល់សិទ្ធិ និង/ឬកាតព្វកិច្ចរបស់ខ្លួនទាំងអស់ឬមួយផ្នែកក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** ដោយមានឬ គ្មានការយល់ព្រមពី**អតិថិជន** (ឬបុគ្គលផ្សេងទៀត) និងៈ

ក. **អតិថិជន**ត្រូវចុះហត្ថលេខាលើឯកសារដែលចាំបាច់ដើម្បីឱ្យ ធនាគារ ព្រីនស៍ ម.ក រួចផុតពីកាតព្វកិច្ចទៅតាមកម្រិតនៃការផ្ទេរ ឬអនុប្បទាន និងចូលរួមជាមួយអ្នកទទួលសិទ្ធិ ឬអនុប្បទានិកជាភាគី។

ខ. ក្នុងករណីធនាគារ ព្រីនស៍ ម.កធ្វើអនុប្បទាន និង/ឬផ្ទេរសិទ្ធិទៅបុគ្គលណាមួយ **អតិថិជន**ត្រូវដោះស្រាយជាមួយនឹងអនុប្បទានិក ឬអ្នកទទួលសិទ្ធិពាក់ព័ន្ធនឹងកិច្ចការនានា ដូចបានកំណត់ក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅនោះ**។

## ១៥. ប្រការផ្សេងៗ

១៥.១.លើកលែងតែមានចែងផ្ទុយពីនេះ បុគ្គលដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ មិនត្រូវមានសិទ្ធិក្នុងការអនុវត្តប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះទេ ។ ដើម្បីជៀសវាងការសង្ស័យ ការយល់ព្រមពីបុគ្គលណាមួយដែលមិនមែនជាភាគីក្នុងកិច្ចព្រមព្រៀងនេះ មិនតម្រូវឱ្យមានក្នុងការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះទេ។

១៥.២.កិច្ចព្រមព្រៀងនេះ បង្កើតជាកិច្ចព្រមព្រៀងទាំងស្រុង រវាង ធនាគារ ព្រីនស៍ ម.ក និង**អតិថិជន** ទាក់ទងនឹង**គណនី** ដែលបានកាន់កាប់ដោយ និង**សេវាកម្ម**ដែលបានផ្តល់ជូន**អតិថិជន**។ មិនមានទំនាក់ទំនងណាផ្សេង រវាងធនាគារ ព្រីនស៍ ម.ក ឬអ្នកតំណាងរបស់ធនាគារ និង**អតិថិជន** បង្កើតជាផ្នែកណាមួយនៃ **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ឡើយ។ តាមអនុញ្ញាតជាអតិបរមារបស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា និងលុះត្រាតែបានចែងក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ** រាល់បញ្ញត្តិ លក្ខខណ្ឌ ការធានា ការសន្យា ការបញ្ចុះបញ្ចូល ឬការអះអាងទាំងអស់ ទោះបីជាដោយច្បាស់លាស់ តណ្ហីភាព តាមច្បាប់ ឬផ្សេងពីនេះ ទាក់ទងនឹង**គណនី ផលិតផល** ឬ**សេវាកម្ម** មិនត្រូវចាត់បញ្ចូលទេ។

១៥.៣.អសុពលភាព ភាពមិនស្របច្បាប់ ឬភាពមិនអាចអនុវត្តបាន នៃបទប្បញ្ញត្តិណាមួយនៃ **បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ** មិនត្រូវប៉ះពាល់ដល់ ឬធ្វើឱ្យខូចខាតដល់ការបន្តជាធរមាននូវប្រការដទៃនៃ **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ឡើយ។ **អតិថិជន** តាមរយៈនេះ យល់ព្រមថា ធនាគារ ព្រីនស៍ ម.ក អាចជំនួសប្រការគ្មានសុពលភាព ឬមិនអាចអនុវត្តបាន ជាមួយនឹងប្រការមានសុពលភាពនិងអាចអនុវត្តបាន ដើម្បីសម្រេចគោលដៅផ្នែកសេដ្ឋកិច្ច ច្បាប់ និងពាណិជ្ជកម្ម របស់ប្រការដែលគ្មានសុពលភាព ឬមិនអាចអនុវត្តបាននោះ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានជាអតិបរមា។

១៥.៤.ការខកខានក្នុងការអនុវត្ត ឬការពន្យាពេលក្នុងការអនុវត្ត សិទ្ធិ ឬការដោះស្រាយណាមួយ ដែលបានផ្តល់ឱ្យក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ឬដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន មិនត្រូវប៉ះពាល់ ឬបង្កើតជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះ ឬការប៉ះពាល់ទៅដល់ ឬការបោះបង់សិទ្ធិ ឬការដោះស្រាយផ្សេងទៀតឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយ ឬមួយផ្នែក ក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ឬច្បាប់ និងបទប្បញ្ញត្តិជាធរមាន រារាំងការអនុវត្តសិទ្ធិ ឬការដោះស្រាយ ឬការអនុវត្តសិទ្ធិ ឬការសង្គ្រោះណាមួយផ្សេងទៀតនៅពេលក្រោយឡើយ។

១៥.៥.ប្រសិនបើ**អតិថិជន**មានចំនួនច្រើនជាងម្នាក់ ឬ**អតិថិជន**កាន់កាប់**គណនី**រួមគ្នា ជាមួយបុគ្គលណាមួយផ្សេងទៀត ម្ចាស់**គណនី**នីមួយៗត្រូវទទួលខុសត្រូវរួមគ្នា ចំពោះកាតព្វកិច្ចរបស់**អតិថិជន** ក្រោម **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** និងការយោងដល់**អតិថិជន**ក្នុង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** មានន័យសំដៅដល់ម្ចាស់**គណនី**នីមួយៗទាំងនោះ។

១៥.៦.**បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** អាចមានចំនួនច្បាប់ចតចម្លងច្រើន ដែលច្បាប់ចតចម្លងនីមួយៗត្រូវចុះហត្ថលេខាដោយភាគីមួយ ឬច្រើន។ ច្បាប់ចតចម្លងដែលចុះហត្ថលេខាទាំងនោះ ត្រូវបង្កើតជាឯកសារតែមួយ។

១៥.៧.ភាពមិនស្របគ្នា

ក. ក្នុងករណីដែលមានភាពមិនស្របគ្នា រវាង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ជាភាសាអង់គ្លេស និងរាល់ច្បាប់បកប្រែនៃ **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ត្រូវយកភាសាខ្មែរជាគោល ។

ខ. ក្នុងករណីដែលមានភាពមិនស្របគ្នារវាងឯកសារខាងក្រោម លើកលែងតែបានចែងផ្សេងពីនេះក្នុងឯកសារពាក់ព័ន្ធ ឯកសារទាំងនោះត្រូវបកស្រាយតាមលំដាប់អាទិភាព ដូចខាងក្រោមៈ

១. **បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់**។
២. **ទម្រង់បែបបទ**។
៣. កិច្ចព្រមព្រៀងជាក់លាក់។

## ១៦. ការជូនដំណឹង

១៦.១.រាល់ការជូនដំណឹង ឬការទំនាក់ទំនងផ្សេងទៀតទាក់ទងនឹង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ត្រូវបានធ្វើឡើងតាមរបៀប ដែលបានចែងខាងក្រោម ទៅអាសយដ្ឋាន លេខទូរស័ព្ទ ឬអ៊ីម៉ែល ដែលបានកំណត់ក្នុងទម្រង់បែបបទពាក្យ សុំ ហើយនឹងត្រូវចាត់ទុកថាមានប្រសិទ្ធិភាព នៅពេលដែលៈ

ក. ប្រសិនបើ ការជូនដំណឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបានបញ្ជូនដោយផ្ទាល់ដៃ ឬដោយអ្នកបញ្ជូនសារ នៅថ្ងៃដែលបានបញ្ជូន។

ខ. ប្រសិនបើ ការជូនដំណឹងត្រូវបានផ្ញើតាមការបញ្ជូនទូរសារ នៅថ្ងៃដែលការបញ្ជូននោះត្រូវបានទទួលក្នុងទម្រង់ដែលអាចមើលឃើញ។

គ. ប្រសិនបើ ការជូនដំណឹងត្រូវបានផ្ញើតាមសារធម្មតា (សារមិនមានការបញ្ជាក់ ឬចុះបញ្ជី) នៅថ្ងៃទីប្រាំនៃ**ថ្ងៃធ្វើប្រតិបត្តិការអាជីវកម្ម** (នៅអាសយដ្ឋានដែលបានបញ្ជូនទៅ) បន្ទាប់ពីបានបញ្ជូន។

ឃ.ប្រសិនបើ ការជូនដំណឹងត្រូវបានផ្ញើតាមសារដែលមានការបញ្ជាក់ ឬចុះបញ្ជី (តាមផ្លូវអាកាសប្រសិនបើ ផ្ញើទៅប្រទេសក្រៅ) ឬប្រហាក់ប្រហែល (ប្រគល់បង្កាន់ដៃស្នើសុំត្រលប់មកវិញ) នៅកាលបរិច្ឆេទ ដែលសារត្រូវបានបញ្ជូន ឬបានប៉ុនប៉ងបញ្ជូន។

ង. ប្រសិនបើការជូនដំណឹងត្រូវបានបញ្ជូនតាមអ៊ីម៉ែល នៅពេលដែលបានបញ្ជូនទៅអ្នកទទួលពាក់ព័ន្ធ លើកលែងតែអ្នកផ្ញើទទួលបានសារស្វ័យប្រវត្តិថា អ៊ីម៉ែលមិនត្រូវបានបញ្ជូន។

១៦.២.រាល់ការជូនដំណឹង ឬការទំនាក់ទំនងផ្សេងទៀតទៅធនាគារ ព្រីនស៍ ម.ក ត្រូវមានប្រសិទ្ធិភាព តែក្នុងករណីដែលបានបញ្ជាក់យ៉ាងច្បាស់ អំពី នាយកដ្ឋាន ឬមន្ត្រី ដូចដែលធនាគារ ព្រីនស៍ ម.ក ជូនដំណឹងទៅ**អតិថិជននៅពេលណាមួយនាពេលអនាគត** ។

## ១៧. ច្បាប់គ្រប់គ្រង និងយុត្តាធិការ

១៧.១.លើកលែងតែមានចែងផ្សេងពីនេះ **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** ត្រូវគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

១៧.២.ក្នុងករណីមានជម្លោះកើតឡើងទាក់ទងនឹង **បញ្ញត្តិ និងលក្ខខណ្ឌទូទៅ** គូភាគីត្រូវដោះស្រាយប្រកបដោយការយោគយល់គ្នា។ ប្រសិនបើ ការដោះស្រាយកិច្ចព្រមព្រៀងនេះ មិនអាចសម្រេចទៅបាន ជម្លោះនោះត្រូវបញ្ជូនទៅតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា

**១៨. ពន្ធ**

ការប្រាក់ទាំងអស់ដែលមាន **គណនី ផលិតផល** និង**សេវាកម្ម** ដែលទទួលខុសត្រូវដោយម្ចាស់ **គណនី/អតិថិជន** ក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** ព្រមទាំងបញ្ញត្តិ និង **លក្ខខណ្ឌជាក់លាក់** ជាកម្មវត្ថុនៃការបង់**ពន្ធ**ដែលបានកំណត់ដោយ**រាជរដ្ឋាភិបាលកម្ពុជា** នៅពេលណាមួយនាពេលអនាគត។ ធនាគារ ព្រីនស៍ ម.ក រក្សាសិទ្ធិក្នុងការដកពីការប្រាក់ដែលបានទទួលជាក់ស្តែងពី**គណនី** ដែលបានកាត់ទុក និងធ្វើការទូទាត់ដោយផ្ទាល់ទៅភ្នាក់ងារពន្ធរបស់**រាជរដ្ឋាភិបាលកម្ពុជា** ក្នុងនាមម្ចាស់**គណនី/អតិថិជន**។

**១៩. អត្រាការប្រាក់ កម្រៃសេវា និងសោហ៊ុយ**

១៩.១.**គណនី**ទាំងអស់ ត្រូវបង់កម្រៃសេវា និងសោហ៊ុយជាក់លាក់ ដែលបានកំណត់ក្នុង "បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់លើអត្រា និងកម្រៃសេវាស្តង់ដារ" របស់ធនាគារ ព្រីនស៍ ម.ក ហើយធនាគារ ព្រីនស៍ ម.ក មានសិទ្ធិក្នុងការធ្វើវិសោធនកម្មនៅពេលណាមួយនាពេលអនាគត ដោយមិនចាំបាច់ជូនដំណឹងជាមុនជូនលោកអ្នក។

១៩.២.នៅពេលដែល**គណនីរបស់លោកអ្នក**បានបើក ឬសេវាកម្មត្រូវបាន ឬកំពុងផ្តល់ឱ្យ លោកអ្នកយល់ព្រមទូទាត់ នូវកម្រៃសេវា និងសោហ៊ុយនានាទៅធនាគារ ព្រីនស៍ ម.ក និងយល់ព្រមថា ធនាគារ ព្រីនស៍ ម.ក អាចធ្វើឥណពន្ធលើកម្រៃសេវា និងសោហ៊ុយនោះ រួមបញ្ចូលទាំងពន្ធកាត់ទុក ដោយផ្ទាល់ពី**គណនី**របស់លោកអ្នក។

១៩.៣.ប្រសិនបើមានការកែប្រែ "បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់លើអត្រា និងកម្រៃសេវាស្តង់ដារ" ណាមួយ ធនាគារ ព្រីនស៍ ម.ក ត្រូវជូនដំណឹងជូន អតិថិជន អំពីការកែប្រែ និងកាលបរិច្ឆេទនៃការអនុវត្តការបង់សោហ៊ុយដែលមានដាក់បង្ហាញនៅលើគេហទំព័រ និង/ឬសាខារបស់ធនាគារ ព្រីនស៍ ម.ក ។

ខ្ញុំ/យើងខ្ញុំ បានអាន យល់ និងឯកភាព គោរពអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌ ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។

| | | |
|---|---|---|
| កាលបរិច្ឆេទ៖___/___/____ | កាលបរិច្ឆេទ៖___/___/____ | កាលបរិច្ឆេទ៖___/___/____ |
| ________________________ | ________________________ | ________________________ |
| ឈ្មោះ៖ | ឈ្មោះ៖ | ឈ្មោះ៖ |
| ទូរស័ព្ទ៖ | ទូរស័ព្ទ៖ | ទូរស័ព្ទ៖ |

## ឧបសម្ព័ន្ធ ១

ពាក្យបានកំណត់ និងនិយមន័យ

| | | |
|---|---|---|
| "គណនី" | ៖ | មានន័យថា គណនីគ្រប់ប្រភេទទាំងអស់ ដែលមាននៅធនាគារ ព្រីនស៍ ម.ក រួមមានជាអាទិ៍ គណនីចរន្ត គណនីបញ្ញើសំចៃ ("CASA") គណនីប្រាក់បញ្ញើមានកាលកំណត់ ("**គណនីប្រាក់បញ្ញើមានកាលកំណត់**") ដែលកាន់កាប់ដោយ **អតិថិជន** និងគណនីផ្សេងទៀតដែលធនាគារ ព្រីនស៍ ម.ក អាចមាននៅពេលណាមួយនាពេលអនាគត។ |
| "រូបិយប័ណ្ណដែលបានព្រមព្រៀង" | ៖ | មានន័យថា រូបិយប័ណ្ណ ដែលបានជ្រើសរើសដោយ**អតិថិជន** និងទទួលការអនុញ្ញាតដោយធនាគារ ព្រីនស៍ ម.ក សម្រាប់ប្រតិបត្តិការជាក់លាក់ណាមួយ ក្រោម បញ្ញត្តិ និង**លក្ខខណ្ឌជាក់លាក់ពាក់ព័ន្ធ**ណាមួយ។ |
| "អត្រាដែលត្រូវអនុវត្ត" | ៖ | មានន័យថា អត្រាប្តូរប្រាក់បច្ចុប្បន្នរបស់ ធនាគារ ព្រីនស៍ ម.ក ឬបើមិនមានការកំណត់ទេទេ អត្រានោះត្រូវកំណត់យ៉ាងសមរម្យដោយធនាគារ ព្រីនស៍ ម.ក។ |
| "បុគ្គលដែលទទួលបានការអនុញ្ញាតិ" | ៖ | មានន័យថា បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យផ្តល់**បញ្ជា** ក្នុងនាម **អតិថិជន** ហើយដែល**អតិថិជន**បានកំណត់អត្តសញ្ញាណបុគ្គលនោះ ជូនទៅធនាគារ ព្រីនស៍ ម.ក ក្នុងបែបបទមួយសមស្រប និងអាចទទួលយកបានពីធនាគារ ព្រីនស៍ ម.ក។ |
| "អាជ្ញាធរ" | ៖ | មានន័យថា និយ័តករ រដ្ឋបាល រដ្ឋាភិបាល អ្នកអនុវត្តច្បាប់ ឬអ្នកត្រួតពិនិត្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ |
| "ថ្ងៃធ្វើប្រតិបត្តិការអាជីវកម្ម" | ៖ | មានន័យថា ថ្ងៃ លើកលែងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យជាតិ ដែលធនាគារ ព្រីនស៍ ម.ក បើកធ្វើប្រតិបត្តិការនូវសកម្មភាពអាជីវកម្មជាធម្មតា ក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** ព្រមទាំងបញ្ញត្តិ និង**លក្ខខណ្ឌជាក់លាក់**ផ្សេងទៀត។ |
| "មូលនិធិច្បាស់លាស់" | ៖ | មានន័យថា មូលនិធិដែលបានដាក់ចូល ឬមានជាឥណទាន ក្នុង**គណនី**ណាមួយដែលធនាគារ ព្រីនស៍ ម.ក បានទទួលការទូទាត់ពេញលេញ និងជាស្ថាពរ ដែលមិនអាចដកយកវិញ ឬលុបចោលបាន។ |
| "អ្នកសម្របសម្រួល" | ៖ | មានន័យថា ស្ថាប័នហិរញ្ញវត្ថុដៃគូជាមួយធនាគារ ព្រីនស៍ ម.ក ណាមួយ ដែលធនាគារ ព្រីនស៍ ម.ក ប្រើប្រាស់សម្រាប់ធ្វើការទូទាត់ដោយផ្ទាល់ ឬដោយប្រយោល ជាមួយអ្នកទទួលប្រាក់ ឬអនុវត្ត**សេវាកម្ម**ណាមួយ ទាក់ទងនឹង **គណនី** ហើយរួមបញ្ចូលទាំង ស្ថាប័នសម្របសម្រួលអន្តរការីណាមួយផងដែរ។ |

**"អតិថិជន"** ៖ មានន័យថា បុគ្គលដែលជា រូបវន្តបុគ្គល មានអាយុយ៉ាងតិច ១៨ ឆ្នាំ ទាំងសញ្ជាតិកម្ពុជា ឬបរទេស ដែលមានអាសយដ្ឋានស្នាក់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ និងនីតិបុគ្គល ដែលបានបង្កើត និងចុះបញ្ជីត្រឹមត្រូវក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**"ពេលកាត់ផ្តាច់"** ៖ មានន័យថា ពេលចុងក្រោយបំផុត (ដែលគូភាគីបានឯកភាព) សម្រាប់ធនាគារ ព្រីនស៍ ម.ក ក្នុងការទទួលនូវ**បញ្ជា**ពី**អតិថិជន**។

**"ព្រឹត្តិការណ៍ប្រធានសក្តិ"** ៖ មានន័យថា ព្រឹត្តិការណ៍ដែលហួសពីការគ្រប់គ្រងរបស់គូភាគី ដែលរារាំងភាគីមួយមិនឱ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោម បញ្ញត្តិ និង**លក្ខខណ្ឌទូទៅ** រួមមានជាអាទិ៍៖

១. គ្រោះធម្មជាតិ (រួមមានជាអាទិ៍ អគ្គិភ័យ ការផ្ទុះ រញ្ជួយផែនដី គ្រោះរាំងស្ងួត ព្យុះ និងគ្រោះទឹកជំនន់។

២. សង្គ្រាម ការវាយប្រយុទ្ធ (ទោះមានការប្រកាសសង្គ្រាម ឬគ្មាន) ការឈ្លានពាន សកម្មភាពរបស់សត្រូវបរទេស ការផ្លាស់ទី ការទាមទារពីរដ្ឋ ឬ ការបិទច្រកពាណិជ្ជកម្ម។

៣ ការប្រឆាំង បដិវត្តន៍ ការបះបោរ ឬការកាន់កាប់ដោយយោធា ឬដោយខុសច្បាប់ ឬសង្គ្រាមស៊ីវិល។

៤. កុបកម្ម ចលាចល កូដកម្ម ការពន្យាពេលធ្វើការ ការឈប់ធ្វើការបណ្តោះអាសន្ន ឬ អសណ្តាប់ធ្នាប់ លុះត្រាតែបានកំហិតផ្តាច់មុខទៅបុគ្គលិករបស់អ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការ។ ឬ

៥. សកម្មភាពឬការគំរាមកំហែងភេរវកម្ម។

**"គណនីរូបិយប័ណ្ណបរទេស"** ៖ មានន័យថា **គណនី**ដែលប្រើប្រាស់រូបិយប័ណ្ណផ្សេងពីខ្មែររៀល (ខ្មែររៀល)។

**"ទម្រង់បែបបទ"** ៖ មានន័យថា ទម្រង់បែបបទបង្កើតឡើងដោយធនាគារ ព្រីនស៍ ម.ក សម្រាប់ប្រតិបត្តិការណាមួយទាក់ទងនឹង**គណនី ផលិតផល** និង/ឬ**សេវាកម្ម** នៅធនាគារ ព្រីនស៍ ម.ក។

**"ធនាគារជាតិ"** ៖ មានន័យថា **ធនាគារជាតិ**នៃកម្ពុជា។

**"ផលិតផល"** ៖ មានន័យថា ឥណទានផ្សេងទៀត ក្រៅពី**គណនី** និង**សេវាកម្ម** ដែលបានផ្តល់

ទៅ**អតិថិជន** ដូចមានចែងក្នុងនេះ ឬនឹងត្រូវផ្តល់ដោយធនាគារ ព្រីនស៍ ម.កពីនៅពេលណាមួយនាពេលអនាគត ។

**"ខ្មែររៀល"** ៖ មានន័យថា រូបិយប័ណ្ណស្របច្បាប់ របស់ព្រះរាជាណាចក្រកម្ពុជានៅពេលណាមួយនាពេលអនាគត ។

**"បញ្ហា"** ៖ មានន័យថា សំណើ និង**បញ្ហា**ទាំងអស់ ទាក់ទងនឹងប្រតិបត្តិការរបស់**គណនី** ឬ **សេវាកម្ម** ដែល **អតិថិជនផ្តល់**ទៅធនាគារ ព្រីនស៍ ម.ក។

**"រាជរដ្ឋាភិបាលកម្ពុជា"** ៖ មានន័យថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។

**"សេវាកម្ម"** ៖ មានន័យថា **សេវាកម្ម**គ្រប់ប្រភេទទាំងអស់ ដែលបានផ្តល់ដោយធនាគារ ព្រីនស៍ ម.ក ទៅ**អតិថិជន**ពាក់ព័ន្ធ ឬទាក់ទងនឹងប្រតិបត្តិការរបស់**គណនី**។

**"ពន្ធ"** ៖ មានន័យថា ប្រាក់ដែលត្រូវបង់ជាកំហិតជូន **រាជរដ្ឋាភិបាលកម្ពុជា** តាមរយៈភ្នាក់ងារ ដែលបានកំណត់នៅពេលណាមួយនាពេលអនាគត។

**"តតិយជន"** ៖ មានន័យថា ស្ថាប័នដែលបានផ្តល់ការទុកចិត្តដោយធនាគារ ព្រីនស៍ ម.ក តាមរយៈកិច្ចព្រមព្រៀង គូភាគីផ្សេងពី ធនាគារ ព្រីនស៍ ម.ក និង**អតិថិជន** សម្រាប់ការដឹកជញ្ជូន ឬធ្វើប្រតិបត្តិលើ**សេវាកម្ម** និង**ផលិតផល** មួយផ្នែក ឬទាំងស្រុង

**"ដុល្លារអាមេរិក"** ៖ មានន័យថា រូបិយប័ណ្ណស្របច្បាប់ របស់សហរដ្ឋអាមេរិកនៅពេលណាមួយនាពេលអនាគត ។